**អេ អិម អេ (ខេមបូឌា) ម.ក**

# របាយការណ៍ក្រុមប្រឹក្សាភិបាល
# និង
# របាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួច
# សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

## អរ អិម អេ (ខេមបូឌា) ម.ក

## របាយការណ៍ក្រុមប្រឹក្សាភិបាល និងរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួច សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

**មាតិកា** **ទំព័រ**


| | |
|---|---|
| របាយការណ៍របស់ក្រុមប្រឹក្សាភិបាល | ១-៥ |
| របាយការណ៍ហិរញ្ញវត្ថុ | |
| របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ | ៦-៧ |
| របាយការណ៍លទ្ធផលលម្អិត | ៨ |
| របាយការណ៍បម្រែបម្រួលមូលធន | ៩ |
| របាយការណ៍លំហូរសាច់ប្រាក់ | ១០ - ១១ |
| កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ | ១២ - ៦៤ |
| របាយការណ៍របស់សវនករឯករាជ្យ | ៦៥ - ៦៩ |

## របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាល ("ឬអភិបាល") បានធ្វើការបង្ហាញជូននូវរបាយការណ៍របស់ខ្លួន ដោយមានភ្ជាប់មកជាមួយនូវរបាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួចរបស់ អ.អិម.អេ (ខេមបូឌា) ម.ក ("ក្រុមហ៊ុន") សម្រាប់ការិយបរិច្ឆេទបញ្ចប់គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣។

### សកម្មភាពអាជីវកម្មចម្បង

សកម្មភាពអាជីវកម្មចម្បងរបស់ក្រុមហ៊ុន គឺការធ្វើសកម្មភាពលក់យានយន្ត គ្រឿងបន្លាស់ គ្រឿងចក្រធុនធ្ងន់ និងការផ្តល់សេវាកម្មជួសជុល និងថែទាំដល់គ្រឿងចក្រធុនធ្ងន់។ នៅក្នុងអំឡុងការិយបរិច្ឆេទនេះពុំមានការផ្លាស់ប្តូរជាសារវន្តលើសកម្មភាពអាជីវកម្មចម្បងទាំងនេះទេ។

### លទ្ធផលប្រតិបត្តិការ

| | **ដុល្លារអាមេរិក** | **ពាន់រៀល** |
|---|---|---|
| ចំណេញសម្រាប់ការិយបរិច្ឆេទ | ២៧.៦៦៩.៨៦២ | ១១៣.៧២៣.១៣៣ |

### ភាគលាភ

ភាគលាភដែលបានប្រកាសដោយក្រុមហ៊ុន និងបានបង់ដោយក្រុមហ៊ុន តាំងពីចុងការិយបរិច្ឆេទមុនមានដូចខាងក្រោមៈ

| | **ដុល្លារអាមេរិក** | **ពាន់រៀល** |
|---|---|---|
| សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ | ៩.៩៤៥.៧៩១ | ៤០.៨៧៧.២០១ |

### សំវិធានធន

ពុំមានការប្រែប្រួលជាសារវន្តទៅលើសំវិធានធនក្នុងការិយបរិច្ឆេទនេះទេ ក្រៅពីអ្វីដែលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុនេះ។

### បំណុលពិបាកទារ និងបំណុលជាប់សង្ស័យ

មុនពេលរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ក្រុមប្រឹក្សាភិបាលបានចាត់វិធានការសមស្របដើម្បីបញ្ជាក់ថាវិធានការទាក់ទងនឹងការលុបចោលបំណុលពិបាកទារ និងការធ្វើសំវិធានធនលើបំណុលជាប់សង្ស័យត្រូវបានធ្វើឡើង ហើយក្រុមប្រឹក្សាភិបាលជឿជាក់ថារាល់បំណុលពិបាកទារដែលបានដឹងត្រូវបានលុបចោល និងបានធ្វើសំវិធានធនគ្រប់គ្រាន់លើបំណុលដែលជាប់សង្ស័យ។

នាកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលនាំឱ្យទឹកប្រាក់នៃបំណុលពិបាកទារដែលបានលុបចោល ឬទឹកប្រាក់នៃសំវិធានធនលើបំណុលជាប់សង្ស័យក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនមានភាពមិនគ្រប់គ្រាន់ជាសារវន្តឡើយ។

## របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

### ទ្រព្យសកម្ម

មុនពេលរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ក្រុមប្រឹក្សាភិបាលបានចាត់វិធានការដែលមានមូលដ្ឋានសមស្រប ដើម្បីធានាថាទ្រព្យសកម្ម ដែលមិនមានតម្លៃស្មើនឹងតម្លៃទីផ្សារនៅក្នុងប្រតិបត្តិការអាជីវកម្មធម្មតា ដែលកត់ត្រាក្នុងបញ្ជីគណនេយ្យរបស់ក្រុមហ៊ុន ត្រូវបានកាត់បន្ថយតម្លៃឱ្យនៅត្រឹមតម្លៃដែលបានរំពឹងទុកនឹងអាចលក់បានលើទីផ្សារ។

នាកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយដែលធ្វើឱ្យប៉ះពាល់ដល់ការកំណត់តម្លៃទ្រព្យសកម្មរយៈពេលខ្លី នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនថាមានភាពមិនត្រឹមត្រូវឡើយ។

### វិធីសាស្ត្រក្នុងការវាយតម្លៃ

នាកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលមិនបានដឹងពីហេតុការណ៍ណាមួយដែលបានកើតឡើងធ្វើឱ្យប៉ះពាល់ដល់ការអនុវត្តន៍វិធីសាស្ត្រដែលមានកន្លងមកក្នុងការវាយតម្លៃទ្រព្យសកម្ម ឬបំណុលនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនថាមានភាពមិនត្រឹមត្រូវ ឬមិនសមស្របនោះទេ។

### បំណុលជាយថាហេតុ និងបំណុលផ្សេងៗ

នាកាលបរិច្ឆេទនៃរបាយការណ៍នេះ ពុំមាន៖

(i) ការទាមទារទ្រព្យសកម្មណាមួយរបស់ក្រុមហ៊ុន ដែលបានកើតឡើងចាប់តាំងពីចុងការិយបរិច្ឆេទ ដើម្បីធានាចំពោះបំណុលរបស់បុគ្គលណាម្នាក់ឡើយ និង

(ii) បំណុលជាយថាហេតុណាមួយ ដែលកើតមានឡើងចំពោះក្រុមហ៊ុនចាប់តាំងពីថ្ងៃចុងការិយបរិច្ឆេទឡើយ។

តាមមតិរបស់ក្រុមប្រឹក្សាភិបាល ពុំមានបំណុលជាយថាហេតុ ឬបំណុលផ្សេងៗទៀតរបស់ក្រុមហ៊ុន ដែលត្រូវទាមទារឱ្យសង ឬអាចនឹងត្រូវទាមទារឱ្យសងក្នុងរយៈពេល១២ខែ បន្ទាប់ពីចុងការិយបរិច្ឆេទដែល នឹងឬអាចធ្វើឱ្យមានផលប៉ះពាល់ដល់លទ្ធភាពរបស់ក្រុមហ៊ុនក្នុងការសងបំណុលនៅថ្ងៃកំណត់សងនោះទេ។

### ការផ្លាស់ប្តូរនៃហេតុការណ៍

នាកាលបរិច្ឆេទនៃរបាយការណ៍នេះ ក្រុមប្រឹក្សាភិបាលពុំបានដឹងពីហេតុការណ៍ណាមួយ ដែលមិនបានបញ្ចូលនៅក្នុងរបាយការណ៍នេះ ឬរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ដែលបណ្តាលឱ្យតួលេខនៃចំនួនណាមួយដែលបានបង្ហាញក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនថាមានភាពមិនត្រឹមត្រូវនោះទេ។

# របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

## ប្រតិបត្តិការជាសារវន្ត និងមិនប្រក្រតី

តាមមតិយោបល់របស់ក្រុមប្រឹក្សាភិបាល៖

(i) លទ្ធផលនៃប្រតិបត្តិការអាជីវកម្មរបស់ក្រុមហ៊ុនក្នុងការិយបរិច្ឆេទ មិនបានទទួលរងនូវឥទ្ធិពលធ្ងន់ធ្ងរដោយកត្តាផ្សេងៗ ប្រតិបត្តិការ ឬព្រឹត្តិការណ៍ដែលមានលក្ខណៈជាសារវន្ត និងមិនប្រក្រតីនោះឡើយ និង

(ii) ពុំមានកត្តា ប្រតិបត្តិការ ឬព្រឹត្តិការណ៍ណាមួយដែលមានលក្ខណៈជាសារវន្ត និងមិនប្រក្រតីនោះទេក្នុងចន្លោះពេលរវាងចុងការិយបរិច្ឆេទ និងកាលបរិច្ឆេទនៃរបាយការណ៍នេះ ដែលអាចនាំឱ្យប៉ះពាល់ជាសារវន្តដល់លទ្ធផលប្រតិបត្តិការរបស់ក្រុមហ៊ុនក្នុងការិយបរិច្ឆេទដែលរៀបចំរបាយការណ៍នេះទេ។

## ការបោះផ្សាយភាគហ៊ុន និងបំណុល

នៅក្នុងអំឡុងការិយបរិច្ឆេទហិរញ្ញវត្ថុ ក្រុមហ៊ុនពុំមានការបោះផ្សាយភាគហ៊ុន ឬប័ណ្ណបំណុលថ្មីនោះឡើយ។

## ក្រុមប្រឹក្សាភិបាល

ក្រុមប្រឹក្សាភិបាលដែលបម្រើការងារក្នុងអំឡុងការិយបរិច្ឆេទ និងអំឡុងពេលចាប់ពីចុងការិយបរិច្ឆេទដល់កាលបរិច្ឆេទនៃរបាយការណ៍ហិរញ្ញវត្ថុនេះរួមមាន៖

Kevin Robert Whitcraft

Thomas Arthur Whitcraft

ងន សាំង

Christopher Gowen Manley

Ith Vichit

## ក្រុមហ៊ុនកាន់កាប់

ក្រុមប្រឹក្សាភិបាលចាត់ទុកក្រុមហ៊ុន Clipper Holdings Limited ជាក្រុមហ៊ុនដែលបានបង្កើតឡើងនៅក្នុងតំបន់រដ្ឋបាលពិសេសហុងកុង និងក្រុមហ៊ុន Whitbro LLC ដែលជាក្រុមហ៊ុនដែលបានបង្កើតឡើងនៅសហរដ្ឋអាមេរិក ជាក្រុមហ៊ុនកាន់កាប់ផ្ទាល់ និងជាក្រុមហ៊ុនមេរបស់ក្រុមហ៊ុនរៀងៗគ្នា។

## ព្រឹត្តិការណ៍សំខាន់ៗបន្ទាប់ពីចុងការិយបរិច្ឆេទ

ព័ត៌មានលម្អិតនៃព្រឹត្តិការណ៍សំខាន់ៗបន្ទាប់ពីចុងការិយបរិច្ឆេទ ត្រូវបានបង្ហាញនៅកំណត់សម្គាល់ ៣០។

## សវនករ

សវនករ បេកឃើរ ធីលលី (ខេមបូឌា) ឯ.ក បានបញ្ជាក់ពីឆន្ទៈដើម្បីបន្តការងារនេះ។

# របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

## ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលលើរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាលទទួលខុសត្រូវលើអំណះអំណាងថា របាយការណ៍ហិរញ្ញវត្ថុត្រូវបានរៀបចំឡើងដោយបង្ហាញនូវទិដ្ឋភាពពិត និងត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់។ ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុនេះក្រុមប្រឹក្សាភិបាលត្រូវ៖

(i) អនុម័តគោលការណ៍គណនេយ្យសមស្រប ដោយអនុលោមតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ("ស.រ.ទ.ហ.អ.ក") ដោយពឹងផ្អែកលើការវិនិច្ឆ័យ និងការប៉ាន់ប្រមាណសមហេតុផល និងប្រកបដោយការប្រុងប្រយ័ត្ន ព្រមទាំងអនុវត្តតាមគោលការណ៍ទាំងនោះឱ្យមានសង្គតិភាព។

(ii) អនុលោមតាមតម្រូវការក្នុងការលាតត្រដាងព័ត៌មាន ដែលអនុលោមតាម ស.រ.ទ.ហ.អ.ក ហើយប្រសិនបើមានការប្រាសចាកណាមួយពីស្តង់ដារទាំងនេះ ក្នុងការបង្ហាញនូវភាពត្រឹមត្រូវ ក្រុមប្រឹក្សាភិបាលត្រូវប្រាកដថា ការប្រាសចាកទាំងនេះត្រូវបានបង្ហាញ ពន្យល់ និងកំណត់បរិមាណឱ្យបានត្រឹមត្រូវក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

(iii) រក្សាទុកកំណត់ត្រាគណនេយ្យឱ្យបានគ្រប់គ្រាន់ ដើម្បីក្រុមហ៊ុនអាចរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ខ្លួនស្របតាម ស.រ.ទ.ហ.អ.ក និងប្រព័ន្ធគ្រប់គ្រងផ្ទៃក្នុងឱ្យមានប្រសិទ្ធភាព។

(iv) រៀបចំរបាយការណ៍ហិរញ្ញវត្ថុដោយប្រើប្រាស់មូលដ្ឋាននិរន្តរភាព លុះត្រាតែវាមានភាពមិនត្រឹមត្រូវក្នុងការសន្មតថាក្រុមហ៊ុននឹងបន្តកិច្ចប្រតិបត្តិការរបស់ខ្លួននាពេលអនាគត និង

(v) ត្រួតពិនិត្យ និងដឹកនាំក្រុមហ៊ុនឱ្យមានប្រសិទ្ធភាពតាមរយៈការសម្រេចចិត្តជាសារវន្តទាំងអស់ដែលអាចប៉ះពាល់ដល់ប្រតិបត្តិការ និងលទ្ធផលរបស់ក្រុមហ៊ុន ហើយត្រូវប្រាកដថាផលប៉ះពាល់ទាំងនោះត្រូវបានឆ្លុះបញ្ចាំងត្រឹមត្រូវនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

ក្រុមប្រឹក្សាភិបាលអះអាងថា ក្រុមហ៊ុនបានអនុវត្តតាមរាល់តម្រូវការខាងលើក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។

**អរ អិម អេ (ខេមបូឌា) ម.ក**

## របាយការណ៍របស់ក្រុមប្រឹក្សាភិបាល

### ការអនុម័តលើរបាយការណ៍ហិរញ្ញវត្ថុ

តាមយោបល់របស់ក្រុមប្រឹក្សាភិបាល របាយការណ៍ហិរញ្ញវត្ថុត្រូវបានរៀបចំដោយអនុលោមតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ហើយបង្ហាញនូវទិដ្ឋភាពពិត និងត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុននាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់នេះហើយកំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុត្រូវបានបង្ហាញត្រឹមត្រូវនូវគ្រប់ទិដ្ឋភាពជាសារវន្តទាំងអស់ ដោយអនុលោមតាមស្តង់ដាររបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា។

ចុះហត្ថលេខាតំណាងឱ្យក្រុមប្រឹក្សាភិបាល

ក្រុមហ៊ុន អរ អិម អេ (ខេមបូឌា) ម.ក
R M A (CAMBODIA) PLC.
KINGDOM OF CAMBODIA

.........................................................

**ងន សាំង**
នាយកប្រតិបត្តិ

ថ្ងៃទី 01 APR 2024

# របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ
# គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

| | កំណត់ | ២០២៣ | | ២០២២ | |
|---|---|---|---|---|---|
| | សម្គាល់ | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| **ទ្រព្យសកម្ម** | | | | | |
| **ទ្រព្យសកម្មរយៈពេលវែង** | | | | | |
| ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ | ៥ | ១៨.៧៦៥.៦៣១ | ៧៦.៦៥៧.៦០៣ | ១៣.២៩៣.៥២៤ | ៥៤.៧២៩.៤៣៨ |
| សិទ្ធិក្នុងការប្រើប្រាស់ទ្រព្យសកម្ម | ៦ | ២៦.៧៩៣.៨២២ | ១០៩.៤៥២.៧៦៣ | ៣.១១៨.៤៤៨ | ១២.៨៣៨.៦៥០ |
| ទ្រព្យសកម្មពន្ធពន្យារសុទ្ធ | ២២ | ២.៤១៨.២៦៧ | ៩.៨៧៨.៦២១ | ២.៩៧៦.២៧៤ | ១២.២៥៣.៣២០ |
| ការវិនិយោគនៅក្នុងក្រុមហ៊ុនញាតិសម្ព័ន្ធ | ៧ | - | - | - | - |
| ការវិនិយោគផ្សេងៗ | ៨ | ៥.៦០០.០០០ | ២២.៨៧៦.០០០ | ៥.៦០០.០០០ | ២៣.០៥៥.២០០ |
| ប្រាក់កក់ | | ៥.៦០០.០០០ | ២២.៨៧៦.០០០ | - | - |
| **ទ្រព្យសកម្មរយៈពេលវែងសរុប** | | **៥៩.១៧៧.៧២០** | **២៤១.៧៤០.៩៨៧** | **២៤.៩៨៨.២៤៦** | **១០២.៨៧៦.៦០៨** |
| **ទ្រព្យសកម្មរយៈពេលខ្លី** | | | | | |
| សន្និធិ | ៩ | ១៥៨.០០១.៣៤៤ | ៦៤៥.៤៣៥.៤៩០ | ១២៥.៧០៦.៨៦៣ | ៥១៧.៥៣៥.១៥៥ |
| គណនីអតិថិជនពាណិជ្ជ | | | | | |
| និងគណនីត្រូវទទួលផ្សេងៗ | ១០ | ២២.២៥៨.៣៥៥ | ៩០.៩២៥.៣៨០ | ១៦.៧៦១.២៦៧ | ៦៩.០០៦.១៣៦ |
| ទឹកប្រាក់ជំពាក់ពីភាគីពាក់ព័ន្ធ | ១១ | ៦.០៨៩.៥០១ | ២៤.៨៧៥.៦១២ | ៦.៤៦៤.៩០៣ | ២៦.៦១៦.០០៦ |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូល | ១២ | ២២.១៦២.៦០៥ | ៩០.៥៣៤.២៤១ | ៤២.០៨៤.៣៦៤ | ១៧៣.២៦១.៣២៧ |
| **ទ្រព្យសកម្មរយៈពេលខ្លីសរុប** | | **២០៨.៥១១.៨០៥** | **៨៥១.៧៧០.៧២៣** | **១៩១.០១៧.៣៩៧** | **៧៨៦.៤១៨.៦២៤** |
| **ទ្រព្យសកម្មសរុប** | | **២៦៧.៦៨៩.៥២៥** | **១.០៩៣.៥១១.៧១០** | **២១៦.០០៥.៦៤៣** | **៨៨៩.២៩៥.២៣២** |
| **បំណុល** | | | | | |
| **បំណុលរយៈពេលខ្លី** | | | | | |
| គណនីត្រូវទូទាត់ពាណិជ្ជ | | | | | |
| និងគណនីត្រូវទូទាត់ផ្សេងៗ | ១៣ | ៩.១៨៨.៦៨៣ | ៣៧.៥៣៥.៧៧០ | ១០.៤៨៣.១៩៥ | ៤៣.១៥៩.៣១៤ |
| បំណុលកិច្ចសន្យា | ១៤ | ៤.៧០៣.៦៩២ | ១៩.២១៤.៥៨២ | ១៣.៥១៨.៤៤៩ | ៥៥.៦៥៥.៤៥៥ |
| ទឹកប្រាក់ជំពាក់ទៅក្រុមហ៊ុនពាក់ព័ន្ធ | ១៥ | ២២.៨២៥.៨១១ | ៩៣.២៤៣.៤៣៨ | ១៥.៧៧០.៣៧៥ | ៦៤.៩២៦.៦៣៤ |
| ឥណទាន និងប្រាក់កម្ចី | ១៦ | ៤៥.៥២៥.៥៧៣ | ១៨៥.៩៧១.៩៦៦ | ៤៤.០៧៣.៣១៧ | ១៨១.៤៤៩.៨៤៥ |
| បំណុលភតិសន្យា | ១៧ | ៨៨៥.២៩៦ | ៣.៦១៦.៤៣៤ | ១.១៧៤.០១៨ | ៤.៨៣៣.៤៣២ |
| បំណុលពន្ធលើប្រាក់ចំណូល | | ១.៨៧០.០១៦ | ៧.៦៣៩.០១៥ | ១១.៦៧០.០៣៩ | ៤៨.០៤៥.៥៥១ |
| សំវិធានធន | | - | - | ៩៩៨.០០០ | ៤.១០៨.៧៦៦ |
| **បំណុលរយៈពេលខ្លីសរុប** | | **៨៤.៩៩៩.០៧១** | **៣៤៧.២២១.២០៥** | **៩៧.៦៨៧.៣៩៣** | **៤០២.១៧៨.៩៩៧** |
| **ទ្រព្យសកម្មរយៈពេលខ្លីសុទ្ធ** | | **១២៣.៥១២.៧៣៤** | **៥០៤.៥៤៩.៥១៨** | **៩៣.៣៣០.០០៤** | **៣៨៤.២៣៩.៦២៧** |

## របាយការណ៍ស្ថានភាពហិរញ្ញវត្ថុ
## គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

| | កំណត់ | ២០២៣ | | ២០២២ | |
|---|---|---|---|---|---|
| | សម្គាល់ | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| **បំណុលរយៈពេលវែង** | | | | | |
| ឥណទាន និងប្រាក់កម្ចី | ១៦ | ៣១.៨០៧.៨៣៤ | ១២៩.៩៣៥.០០២ | ៩.៥៧០.៤៩៨ | ៣៩.៤០១.៧៤០ |
| បំណុលភតិសន្យា | ១៧ | ២៦.៧៩៤.០១២ | ១០៩.៤៥៣.៥៣៩ | ២.៣៨៣.២១៥ | ៩.៨១១.៦៩៦ |
| **បំណុលរយៈពេលវែងសរុប** | | **៥៨.៦០១.៨៤៦** | **២៣៩.៣៨៨.៥៤១** | **១១.៩៥៣.៧១៣** | **៤៩.២១៣.៤៣៦** |
| **បំណុលសរុប** | | **១៤៣.៦០០.៩១៧** | **៥៨៦.៦០៩.៧៤៦** | **១០៩.៦៤១.១០៦** | **៤៥១.៣៩២.៤៣៣** |
| **ទ្រព្យសកម្មសុទ្ធ** | | **១២៤.០៨៨.៦០៨** | **៥០៦.៩០១.៩៦៤** | **១០៦.៣៦៤.៥៣៧** | **៤៣៧.៩០២.៧៩៩** |
| | | | | | |
| **មូលធន** | | | | | |
| ដើមទុន | ១៨ | ៤.០០០.០០០ | ១៦.០០០.០០០ | ៤.០០០.០០០ | ១៦.០០០.០០០ |
| ចំណេញរក្សាទុក | | ១២០.០៨៨.៦០៨ | ៤៨៩.៧៥១.៤០៧ | ១០២.៣៦៤.៥៣៧ | ៤១៦.៩០៥.៤៧៥ |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | ២ | - | ១.១៥០.៥៥៧ | - | ៤.៩៩៧.៣២៤ |
| **មូលធនសរុប** | | **១២៤.០៨៨.៦០៨** | **៥០៦.៩០១.៩៦៤** | **១០៦.៣៦៤.៥៣៧** | **៤៣៧.៩០២.៧៩៩** |

កំណត់សម្គាល់ដូចមានភ្ជាប់ជាមួយគឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

# របាយការណ៍លទ្ធផលលម្អិត
# សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

| | កំណត់ | ២០២៣ | | ២០២២ | |
|---|---|---|---|---|---|
| | សម្គាល់ | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ចំណូល | ១៩ | ៤៣៨.០៤៤.៣០៥ | ១.៨០០.៣៦២.០៩៤ | ៥៣៩.០៨៨.១៩៥ | ២.២០៣.២៥៣.៤៥៣ |
| ថ្លៃដើម | | (៣៦១.៩០៥.៤៥៩) | (១.៤៨៧.៤៣១.៤៣៦) | (៤៣៦.៨១៣.១២៣) | (១.៧៨៥.២៥៥.២៣៤) |
| **ចំណេញដុល** | | **៧៦.១៣៨.៨៤៦** | **៣១២.៩៣០.៦៥៨** | **១០២.២៧៥.០៧២** | **៤១៧.៩៩៨.២១៩** |
| | | | | | |
| ចំណូលផ្សេងៗ | | ១.៦៨៨.១៩៤ | ៦.៩៣៨.៤៧៧ | ៣.៣៦៤.៤១០ | ១៣.៧៥០.៣៤៤ |
| ចំណាយទីផ្សារ | | (៦.៤៤៥.៩៦៧) | (២៦.៤៩២.៩២៤) | (៥.៩៦០.៣៨៨) | (២៤.៣៦០.១០៦) |
| ចំណាយរដ្ឋបាល | ២០ | (១៥.១០៦.៩៣២) | (៦២.០៨៩.៤៩១) | (១១.៣៧៨.៩១២) | (៤៦.៥០៥.៦១៣) |
| ចំណាយប្រតិបត្តិការ | ២១ | (១៥.១៩៥.៦១៣) | (៦២.៤៥៣.៩៦៩) | (១២.៧២៨.៦៤៩) | (៥២.០២១.៩៨៨) |
| **ចំណេញប្រតិបត្តិការ** | | **៤១.០៧៨.៥២៨** | **១៦៨.៨៣២.៧៥១** | **៧៥.៥៧១.៥៣៣** | **៣០៨.៨៦០.៨៥៦** |
| | | | | | |
| ចំណាយហិរញ្ញប្បទាន | | (៧.១៥៦.៣១៤) | (២៩.៤១២.៤៥១) | (៣.១៣២.៣៥៧) | (១២.៨០១.៩៤៣) |
| ចំណែកនៃការខាតបង់ពីការវិនិយោគ នៅក្នុងក្រុមហ៊ុនញាតិសម្ព័ន្ធ | | - | - | - | - |
| **ចំណេញមុនបង់ពន្ធ** | | **៣៣.៩២២.២១៤** | **១៣៩.៤២០.៣០០** | **៧២.៤៣៩.១៧៦** | **២៩៦.០៥៨.៩១៣** |
| | | | | | |
| ពន្ធលើប្រាក់ចំណូល | ២២ | (៦.២៥២.៣៥២) | (២៥.៦៩៧.១៦៧) | (១២.៨៤៣.៩៨៩) | (៥២.៤៩៣.៣៨៣) |
| **ចំណេញសម្រាប់ការិយបរិច្ឆេទ** | | **២៧.៦៦៩.៨៦២** | **១១៣.៧២៣.១៣៣** | **៥៩.៥៩៥.១៨៧** | **២៤៣.៥៦៥.៥៣០** |
| | | | | | |
| **លទ្ធផលលម្អិតផ្សេងៗក្រោយបង់ពន្ធ** | | | | | |
| ធាតុដែលអាចមិនត្រូវបានចាត់ថ្នាក់ ឡើងវិញទៅចំណេញ ឬខាត | | | | | |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | (៣.៨៤៦.៧៦៧) | - | ៤.១០៣.២៩៣ |
| **លទ្ធផលចំណូលលម្អិតសរុប សម្រាប់ការិយបរិច្ឆេទ** | | **២៧.៦៦៩.៨៦២** | **១០៩.៨៧៦.៣៦៦** | **៥៩.៥៩៥.១៨៧** | **២៤៧.៦៦៨.៨២៣** |

កំណត់សម្គាល់ដូចមានភ្ជាប់ជាមួយគឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

# របាយការណ៍បម្រែបម្រួលមូលធន
# សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

| | កំណត់សម្គាល់ | ដើមទុន<br>ដុល្លារអាមេរិក | ចំណេញរក្សាទុក<br>ដុល្លារអាមេរិក | លម្អៀងពីការប្តូររូបិយប័ណ្ណ<br>ដុល្លារអាមេរិក | មូលធនសរុប<br>ដុល្លារអាមេរិក |
|---|---|---|---|---|---|
| **នាថ្ងៃទី១ ខែមករា ឆ្នាំ២០២២** | | ៤.០០០.០០០ | ៦៦.១៨១.៣២៣ | - | ៧០.១៨១.៣២៣ |
| ចំណេញ និងលទ្ធផលលម្អិតសរុប សម្រាប់ការិយបរិច្ឆេទ | | - | ៥៩.៥៥៥.១៨៧ | - | ៥៩.៥៥៥.១៨៧ |
| **ប្រតិបត្តិការជាមួយម្ចាស់ក្រុមហ៊ុន** | | | | | |
| ភាគលាភ | ២៤ | - | (២៣.៤១១.៩៧៣) | - | (២៣.៤១១.៩៧៣) |
| **នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២/ ១ មករា ២០២៣** | | ៤.០០០.០០០ | ១០២.៣៦៤.៥៣៧ | - | ១០៦.៣៦៤.៥៣៧ |
| ចំណេញ និងលទ្ធផលលម្អិតសរុប សម្រាប់ការិយបរិច្ឆេទ | | - | ២៧.៦៦៩.៨៦២ | - | ២៧.៦៦៩.៨៦២ |
| **ប្រតិបត្តិការជាមួយម្ចាស់ក្រុមហ៊ុន** | | | | | |
| ភាគលាភ | ២៤ | - | (៩.៩៤៥.៧៩១) | - | (៩.៩៤៥.៧៩១) |
| **នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣** | | ៤.០០០.០០០ | ១២០.០៨៨.៦០៨ | - | ១២៤.០៨៨.៦០៨ |
| **នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ (ពាន់រៀល)** | | ១៦.០០០.០០០ | ៤១៦.៩០៥.៤៧៥ | ៤.៩៩៧.៣២៤ | ៤៣៧.៩០២.៧៩៩ |
| **នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ (ពាន់រៀល)** | | ១៦.០០០.០០០ | ៤៨៩.៧៥១.៤០៧ | ១.១៥០.៥៥៧ | ៥០៦.៩០១.៩៦៤ |

កំណត់សម្គាល់ដូចមានភ្ជាប់ជាមួយគឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

## **របាយការណ៍លំហូរសាច់ប្រាក់**
## **សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣**

| | កំណត់សម្គាល់ | ២០២៣ ដុល្លារអាមេរិក | ២០២៣ ពាន់រៀល | ២០២២ ដុល្លារអាមេរិក | ២០២២ ពាន់រៀល |
|---|---|---|---|---|---|
| **សកម្មភាពប្រតិបត្តិការ** | | | | | |
| **ចំណេញមុនបង់ពន្ធ** | | **៣៣.៩២២.២១៤** | **១៣៩.៤២០.៣០០** | **៧២.៤៣៩.១៧៦** | **២៩៦.០៥៨.៩១៣** |
| **និយ័តកម្ម៖** | | | | | |
| ចំណូលភាគលាភ | ៨ | - | - | (៥០០.១២០) | (២.០៤៣.៩៩០) |
| ចំណាយហិរញ្ញប្បទាន | | ៧.១៥៦.៣១៤ | ២៩.៤១២.៤៥១ | ៣.១៣២.៣៥៧ | ១២.៨០១.៩៤៣ |
| ចំណូលហិរញ្ញប្បទាន | | (៦៣៨.០៩៧) | (២.៦២២.៥៧៩) | (១.១៧៥.៨៤១) | (៤.៨០៥.៦៦២) |
| (ចំណេញ) / ខាតមិនជាក់ស្តែង | | | | | |
| ពីការប្តូររូបិយប័ណ្ណសុទ្ធ | | (៣៥.៤៣២) | (១៤៥.៦២៦) | ១១.៣៥៨ | ៤៦.៤២០ |
| ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ | | | | | |
| - រំលស់ | ៥ | ៣.៦៦៦.៥៧៨ | ១៥.០៦៩.៦៣៦ | ៣.២១៥.១០៩ | ១៣.១៤០.១៥០ |
| - ចំណេញពីការលក់ | ៥ | (២៣៣.០៥៧) | (៩៥៧.៨៦៤) | (៦៩.៧៥៣) | (២៨៥.០៨១) |
| - ការលុបចោល | ៥ | - | - | ៤៣.០៨០ | ១៧៦.០៦៨ |
| ការកត់ត្រឡប់នៃការខាតបង់ឱនភាពតម្លៃ | | | | | |
| លើគណនីអតិថិជនពាណិជ្ជ | | (៦.២៦១) | (២៥.៧៣៣) | (៧៨២.៥៩៣) | (៣.១៩៨.៤៥៨) |
| (ការកត់ត្រឡប់) / សំវិធានធនលើការធានា | | (៩៩៨.០០០) | (៤.១០១.៧៨០) | ៩៩៨.០០០ | ៤.០៧៨.៨២៦ |
| ឱនភាពតម្លៃពីការវិនិយោគ | | | | | |
| នៅក្នុងក្រុមហ៊ុនពាក់ព័ន្ធ | ៧ | - | - | ២៥០.០០០ | ១.០២១.៧៥០ |
| សិទ្ធិក្នុងការប្រើប្រាស់ទ្រព្យសកម្ម | | | | | |
| - រំលស់ | ៦ | ១.៦១៦.៤៨០ | ៦.៦៤៣.៧៣៣ | ១.២២៥.៣៨៤ | ៥.០០៨.១៤៤ |
| - ខាតពីការឈប់ទទួលស្គាល់ | | (២៨.២៩៧) | (១១៦.៣០១) | - | - |
| សន្និធិដែលមានចលនាយឺតយ៉ាវ | | | | | |
| - សំវិធានធន | ៩ | ២.៤៩៤.៣៤៧ | ១០.២៥១.៧៦៦ | ៣.១៤២.៦៣០ | ១២.៨៤៣.៩២៩ |
| - ការកត់ត្រឡប់នៃសំវិធានធន | ៩ | (១.៩៣៧.១១៩) | (៧.៩៦១.៥៥៩) | (៨៦៣.២៣២) | (៣.៥២៨.០២៩) |
| - ការលុបចោល | ៩ | (២៤៤.៣០៦) | (១.០០៤.០៩៨) | (៣៤៤.០៩២) | (១.៤០៦.៣០៤) |
| **ចំណេញប្រតិបត្តិការ** | | | | | |
| **មុនបម្រែបម្រួលទុនបង្វិល** | | **៤៤.៧៣៥.៣៦៤** | **១៨៣.៨៦២.៣៤៦** | **៨០.៧២១.៤៦៣** | **៣២៩.៩០៨.៦១៩** |
| | | | | | |
| **បម្រែបម្រួលទុនបង្វិល៖** | | | | | |
| សន្និធិ | | (៣៦.៨៨១.៣១៥) | (១៥១.៥៨២.២០៥) | (៦៤.៧៩២.៧៨៦) | (២៦៤.៨០៨.១១៦) |
| គណនីអតិថិជនពាណិជ្ជ | | | | | |
| និងគណនីត្រូវទទួលផ្សេងៗ | | (៦.០៦២.១៨៤) | (២៤.៩១៥.៥៧៦) | (៣.៣២១.៤៨៥) | (១៣.៥៧៤.៩០៩) |
| ជំពាក់ពីក្រុមហ៊ុនពាក់ព័ន្ធ | | ៣៧៥.៤០២ | ១.៥៤២.៩០២ | (១.៩៧១.៧៤២) | (៨.០៥៨.៥០៩) |
| គណនីត្រូវទូទាត់ពាណិជ្ជ | | | | | |
| និងគណនីត្រូវទូទាត់ផ្សេងៗ | | (១.១៣៣.០៨៩) | (៤.៦៥៦.៩៩៦) | (១.៣៨២.៣៦២) | (៥.៦៤៩.៧១៣) |
| ជំពាក់ទៅក្រុមហ៊ុនពាក់ព័ន្ធ | | ៧.០៥៥.៤៣៦ | ២៨.៩៩៧.៨៤២ | ១៤.៣៨៤.៣១៥ | ៥៨.៧៨៨.៦៩៥ |
| បំណុលកិច្ចសន្យា | | (៨.៨១៤.៧៥៧) | (៣៦.២២៨.៦៥១) | (៧.៤៣២.៤៦៤) | (៣០.៣៧៦.៤៨០) |
| ប្រាក់កក់ | | (៥.៦០០.០០០) | (២៣.០១៦.០០០) | - | - |
| **សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុង/** | | | | | |
| **បានពីប្រតិបត្តិការ** | | **(៦.៣២៥.១៤៣)** | **(២៥.៩៩៦.៣៣៨)** | **១៦.២០៤.៩៣៩** | **៦៦.២២៩.៥៨៧** |

# របាយការណ៍លំហូរសាច់ប្រាក់
# សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

| | កំណត់សម្គាល់ | ២០២៣ ដុល្លារអាមេរិក | ២០២៣ ពាន់រៀល | ២០២២ ដុល្លារអាមេរិក | ២០២២ ពាន់រៀល |
|---|---|---|---|---|---|
| ការប្រាក់ទទួលបាន | | ១.២២៨.៧១៤ | ៥.០៥០.០១៥ | ៩៨៦.១៧៧ | ៤.០៣០.៥០៥ |
| ការប្រាក់បានបង់ | | (៦.៩១២.៥១០) | (២៨.៤១០.៤១៦) | (២.៥៤៣.២៩៦) | (១០.៣៩៤.៤៥១) |
| ពន្ធលើប្រាក់ចំណូលបានបង់ | | (១៥.៦៩៧.០៧៦) | (៦៤.៥១៤.៩៨២) | (៧.៩៩៦.៤១៤) | (៣២.៦៨១.៣៤៤) |
| **សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុង / បានពី សកម្មភាពប្រតិបត្តិការ** | | **(២៧.៧០៦.០១៥)** | **(១១៣.៨៧១.៧២១)** | **៦.៦៥១.៤០៦** | **២៧.១៨៤.២៩៧** |
| **សកម្មភាពវិនិយោគ** | | | | | |
| សាច់ប្រាក់បានពីការលក់ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ | | ១.៦៣០.៤៦៧ | ៦.៧០១.២១៩ | ៥៩៧.៩២០ | ២.៤៤៣.៦៩៩ |
| ការទិញវិនិយោគក្នុងក្រុមហ៊ុនញាតិសម្ព័ន្ធ | | - | - | (២៥០.០០០) | (១.០២១.៧៥០) |
| ការទិញវិនិយោគផ្សេងៗ | | - | - | (៦០០.០០០) | (២.៤៥២.២០០) |
| ការទិញទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ | ៥ | (៦.២៦២.១៨៣) | (២៥.៧៣៧.៥៧២) | (៣.៥៤២.១៨៨) | (១៤.៤៧៦.៩២២) |
| ភាគលាភទទួលបាន | | - | - | ៥០០.១២០ | ២.០៤៣.៩៩០ |
| **សាច់ប្រាក់សុទ្ធប្រើប្រាស់ក្នុង សកម្មភាពវិនិយោគ** | | **(៤.៦៣១.៧១៦)** | **(១៩.០៣៦.៣៥៣)** | **(៣.២៩៤.១៤៨)** | **(១៣.៤៦៣.១៨៣)** |
| **សកម្មភាពហិរញ្ញប្បទាន** | | | | | |
| ហិរញ្ញប្បទានពាណិជ្ជ ដែលបានបោះផ្សាយថ្មី | ២៣ | ១៥៩.៥៤០.៣៥០ | ៦៥៥.៧១០.៨៣៩ | ២៣៤.៣១៥.៦៤៦ | ៩៥៧.៦៤៨.០៤៥ |
| ឥណទានមានកំណត់ដែលបាន បោះផ្សាយថ្មី | ២៣ | ៣០.០០០.០០០ | ១២៣.៣០០.០០០ | - | - |
| បម្រែបម្រួលការធានាលើមូលបត្របំណុល | | ៤.០២៨.៥៣១ | ១៦.៥៥៧.២៦២ | (៣.៥១១.១២២) | (១៤.៣៤៩.៩៥៦) |
| ការទូទាត់បំណុលភតិសន្យា | ២៣ | (១.១៤១.៤៨២) | (៤.៦៩១.៤៩១) | (១.១៣៥.២១៩) | (៤.៦៣៩.៦៤០) |
| ការទូទាត់មូលបត្របំណុល | ២៣ | (៣.៨៣៨.៨៩៩) | (១៥.៧៧៧.៨៧៥) | (៣.០០៩.៥៩០) | (១២.៣០០.១៩៤) |
| ភាគលាភបានបង់ | | (៩.៩៤៥.៧៩១) | (៤០.៨៧៧.២០១) | (២៧.២១៧.៧៧៣) | (១១១.២៣៩.០៣៨) |
| ការទូទាត់ហិរញ្ញប្បទានពាណិជ្ជ | ២៣ | (១៦២.១៩៨.២០៦) | (៦៦៦.៦៣៤.៦២៧) | (២០៧.៤៥៤.៣១១) | (៨៤៧.៨៦៥.៧៦៩) |
| **សាច់ប្រាក់សុទ្ធបានពី/(ប្រើប្រាស់ក្នុង) សកម្មភាពហិរញ្ញប្បទាន** | | **១៦.៤៤៤.៥០៣** | **៦៧.៥៨៦.៩០៧** | **(៨.០១២.៣៦៩)** | **(៣២.៧៤៦.៥៥២)** |
| **តំហយសាច់ប្រាក់ និងសាច់ប្រាក់សមមូលសុទ្ធ** | | **(១៥.៨៩៣.២២៨)** | **(៦៥.៣២១.១៦៧)** | **(៤.៦៥៥.១១១)** | **(១៩.០២៥.៤៣៨)** |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូល នាថ្ងៃទី១ ខែមករា** | | **៣៧.៤៩១.៣៦៣** | **១៥៤.៣៥១.៩៤២** | **៤២.១៤៦.៤៧៤** | **១៧១.៧០៤.៧៣៥** |
| លម្អៀងពីការប្តូររូបិយប័ណ្ណ | | - | (៨០២.៣៩៤) | - | ១.៦៧២.៦៤៥ |
| **សាច់ប្រាក់ និងសាច់ប្រាក់សមមូល នាថ្ងៃទី៣១ ខែធ្នូ** | ១២ | **២១.៥៩៨.១៣៥** | **៨៨.២២៨.៣៨១** | **៣៧.៤៩១.៣៦៣** | **១៥៤.៣៥១.៩៤២** |

កំណត់សម្គាល់ដូចមានភ្ជាប់ជាមួយគឺជាផ្នែកមួយនៃរបាយការណ៍ហិរញ្ញវត្ថុនេះ។

# កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ
# សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

## ១. ព័ត៌មានអំពីក្រុមហ៊ុន

អ អិម អេ (ខេមបូឌា) ម.ក ហៅកាត់ថា ("ក្រុមហ៊ុន") ជាក្រុមហ៊ុនសាធារណៈទទួលខុសត្រូវមានកម្រិតដែលបានចុះបញ្ជីពាណិជ្ជកម្ម និងមានទីស្នាក់ការនៅព្រះរាជាណាចក្រកម្ពុជា។ ការិយាល័យចុះបញ្ជី និងអាសយដ្ឋានអាជីវកម្មរបស់ក្រុមហ៊ុនស្ថិតនៅផ្ទះលេខ ២៧ E១ ផ្លូវ ១៣៤ សង្កាត់មិត្តភាព ខណ្ឌ៧មករា រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា។

សកម្មភាពអាជីវកម្មចម្បងរបស់ក្រុមហ៊ុន គឺការធ្វើសកម្មភាពលក់យានយន្ត គ្រឿងបន្លាស់ គ្រឿងចក្រធុនធ្ងន់ និងការផ្តល់សេវាកម្មជួសជុល និងថែទាំគ្រឿងចក្រធុនធ្ងន់។ នៅក្នុងអំឡុងការិយបរិច្ឆេទហិរញ្ញវត្ថុនេះ ពុំមានការផ្លាស់ប្តូរជាសារវន្តលើសកម្មភាពអាជីវកម្មចម្បងៗទាំងនេះទេ។

នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ អភិបាលបានចាត់ទុកក្រុមហ៊ុនកាន់កាប់ផ្ទាល់ និងក្រុមហ៊ុនមេរបស់ខ្លួនគឺមានក្រុមហ៊ុន Clipper Holdings Limited ដែលជាក្រុមហ៊ុនបានឡើងនៅក្នុងតំបន់រដ្ឋបាលពិសេសហុងកុង និងក្រុមហ៊ុន Whitbro LLC ដែលជាក្រុមហ៊ុនបានបង្កើតឡើងនៅសហរដ្ឋអាមេរិករៀងៗគ្នា។

## ២. ព័ត៌មានគោលការណ៍គណនេយ្យសំខាន់ៗ

### (ក) មូលដ្ឋាននៃការរៀបចំរបាយការណ៍ហិរញ្ញវត្ថុ

#### សេចក្តីថ្លែងការណ៍នៃការអនុលោមភាព

របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន បានរៀបចំឡើងអនុលោមតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ("ស.រ.ទ.ហ.អ.ក")។

#### មូលដ្ឋាននៃការវាស់វែង

របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន បានរៀបចំតាមវិធីសាស្ត្រថ្លៃដើមប្រវត្តិសាស្ត្រ លើកលែងតែមានបង្ហាញផ្សេងពីនេះនៅក្នុងគោលការណ៍គណនេយ្យសំខាន់ៗ។

ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុស្របតាម ស.រ.ទ.ហ.អ.ក តម្រូវឱ្យអ្នកគ្រប់គ្រងប្រើការវិនិច្ឆ័យ ប៉ាន់ស្មាន និងសន្មតពីការអនុវត្តគោលការណ៍ និងចំនួនទឹកប្រាក់ដែលត្រូវបានរាយការណ៍ពីទ្រព្យសកម្ម បំណុល ចំណូល និងចំណាយ។ ការប៉ាន់ស្មាន និងការសន្មតនេះត្រូវពឹងផ្អែកលើបទពិសោធន៍កន្លងមក និងកត្តាផ្សេងៗទៀតជាច្រើនដែលត្រូវបានជឿជាក់ថាសមហេតុផលក្នុងកាលៈទេសៈណាមួយ លទ្ធផលដែលទទួលបានគឺត្រូវបានប្រើជាមូលដ្ឋានសម្រាប់ធ្វើការវិនិច្ឆ័យអំពីតម្លៃយោងទ្រព្យសកម្ម និងបំណុលដែលមិនបានបង្ហាញជាក់ស្តែងតាមប្រភពផ្សេងៗនោះទេ។ លទ្ធផលជាក់ស្តែងអាចខុសគ្នាពីការសន្មតទាំងនេះ។

មូលដ្ឋាននៃការប៉ាន់ស្មាន និងការសន្មតត្រូវបានពិនិត្យឡើងវិញជាប្រចាំ។ កំណែសម្រួលគណនេយ្យប៉ាន់ស្មាន ត្រូវបានទទួលស្គាល់នៅក្នុងរយៈពេលដែលការប៉ាន់ស្មានត្រូវបានកែសម្រួល ប្រសិនបើការកែសម្រួលនេះប៉ះពាល់តែក្នុងរយៈពេលនោះ ឬក៏ក្នុងអំឡុងពេលកែសម្រួល និងនៅពេលអនាគតប្រសិនបើការកែសម្រួលនោះប៉ះពាល់ទាំងបច្ចុប្បន្ន និងពេលអនាគត ។

ផ្នែកដែលទាក់ទងនឹងការវិនិច្ឆ័យ ឬមានភាពស្មុគស្មាញក្នុងកម្រិតខ្ពស់ ឬផ្នែកដែលការសន្មត និងការប៉ាន់ស្មានមានលក្ខណៈជាសារវន្តចំពោះរបាយការណ៍ហិរញ្ញវត្ថុ ត្រូវបានបង្ហាញនៅក្នុងកំណត់សម្គាល់ ៤។

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

### ២. ព័ត៌មានគោលការណ៍គណនេយ្យសំខាន់ៗ(ត)

### (ខ) រូបិយប័ណ្ណមុខងារ និងរូបិយប័ណ្ណសម្រាប់បង្ហាញ

រូបិយប័ណ្ណជាតិនៃប្រទេសកម្ពុជា គឺប្រាក់រៀល។ ប៉ុន្តែក្រុមហ៊ុនមានប្រតិបត្តិការអាជីវកម្ម និងរក្សាកំណត់ត្រាបញ្ជីគណនេយ្យរបស់ខ្លួនជាប្រាក់ដុល្លារអាមេរិក ហើយប្រធានក្រុមប្រឹក្សាភិបាលបានកំណត់ប្រាក់ដុល្លារអាមេរិកជារូបិយប័ណ្ណមុខងាររបស់ក្រុមហ៊ុន ដែលប្រើប្រាស់សម្រាប់ការវាស់វែង និងការធ្វើបទបង្ហាញដែលឆ្លុះបញ្ចាំងពីស្ថានភាពព្រឹត្តិការណ៍សេដ្ឋកិច្ច និងកាលៈទេសៈរបស់ក្រុមហ៊ុន។

ការប្តូររូបិយប័ណ្ណពីប្រាក់ដុល្លារអាមេរិកទៅជាប្រាក់រៀល ដែលបានបង្ហាញនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ គឺស្របតាមតម្រូវការនៃច្បាប់ស្តីពីគណនេយ្យ និងសវនកម្ម ហើយអត្រាប្តូរប្រាក់ចុងគ្រា និងអត្រាប្តូរប្រាក់មធ្យមដែលបានប្រើប្រាស់គឺ ១ដុល្លារអាមេរិក ស្មើនឹង ៤.០៨៥រៀល និង៤.១១០រៀល រៀងៗគ្នាសម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ (២០២២៖ ៤.១១៧រៀល និង៤.០៨៧រៀល) គឺដូចបានប្រកាសដោយធនាគារជាតិនៃកម្ពុជា។

ការប្តូរប្រាក់នេះ មិនគួរត្រូវបានបកស្រាយថាជាតំណាងដែលចំនួនទឹកប្រាក់ដុល្លារអាមេរិកត្រូវបាន ឬអាចត្រូវបាន ឬនឹងប្តូរទៅជាប្រាក់រៀលតាមអត្រាប្តូរប្រាក់នេះ ឬអត្រាប្តូរប្រាក់ដទៃទៀតឡើយ។

លម្អៀងពីការប្តូររូបិយប័ណ្ណកើតឡើងពីការបកប្រែរបាយការណ៍ហិរញ្ញពីប្រាក់ដុល្លារអាមេរិក ទៅប្រាក់រៀល។

### (គ) ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ

ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារទាំងអស់ ត្រូវបានទទួលស្គាល់ជាដំបូងនៅថ្លៃដើម ហើយយោងទៅមុខដោយថ្លៃដើមដករំលស់បង្គរ និងឱនភាពនៃតម្លៃបង្គរ។ ថ្លៃដើមនៃទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ ដែលត្រូវបានទទួលស្គាល់រួមមានថ្លៃទំនិញ និងថ្លៃដើមណាមួយដែលបាននាំទ្រព្យសកម្មទៅទីតាំង និងលក្ខខណ្ឌចាំបាច់ដើម្បីឱ្យវាមានសមត្ថភាពធ្វើប្រតិបត្តិការដូចដែលបានកំណត់ដោយអ្នកគ្រប់គ្រង។

ចំណាយនៃការផ្លាស់ប្តូរផ្នែកណាមួយនៃទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ ត្រូវបានទទួលស្គាល់នៅតម្លៃយោងនៃទ្រព្យសកម្មប្រសិនបើមានភាពប្រាកដថាផលប្រយោជន៍សេដ្ឋកិច្ចនាពេលអនាគត ដែលពាក់ព័ន្ធនឹងទ្រព្យសកម្មនោះ នឹងហូរចូលមកក្នុងក្រុមហ៊ុនហើយចំណាយទាំងនោះអាចត្រូវបានវាស់វែងគួរឱ្យជឿជាក់។ តម្លៃយោងនៃផ្នែករបស់ទ្រព្យសកម្មដែលត្រូវបានផ្លាស់ប្តូរ ត្រូវបានឈប់ទទួលស្គាល់។

ចំពោះទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារដែលបានលក់ចោល ភាពខុសគ្នារវាងសាច់ប្រាក់ដែលបានពីការលក់ និងតម្លៃយោងនឹងត្រូវកត់ត្រាទៅក្នុងរបាយការណ៍ចំណេញ ឬខាត។

ទ្រព្យសកម្មកំពុងសាងសង់ ដែលរួមបញ្ចូលក្នុងទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ មិនត្រូវបានយកមកធ្វើរំលស់ទេដោយសារតែទ្រព្យសកម្មទាំងនោះមិនទាន់អាចប្រើប្រាស់បាន។

# កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ
# សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

## ២. ព័ត៌មានគោលការណ៍គណនេយ្យសំខាន់ៗ (ត)

### (គ) ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ (ត)

រំលស់ត្រូវបានគណនាតាមវិធីសាស្ត្ររំលស់ថេរដើម្បីទូទាត់ថ្លៃដើមទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារទាំងអស់លើអាយុកាលប្រើប្រាស់រំពឹងទុក។ អាយុកាលប្រើប្រាស់រំពឹងទុកមានដូចខាងក្រោម៖

| | ឆ្នាំ |
|---|---|
| អាគារ | ១០ |
| ឧបករណ៍សម្រាប់សេវាកម្ម និងបរិក្ខារឃ្លាំង | ៥ |
| គ្រឿងសង្ហារឹម និងបរិក្ខារបំពាក់ | ៤ |
| ការកែលម្អ ការជួល | ៥ - ១០ |
| យានយន្ត | ៥ |
| ឧបករណ៍សម្រាប់ប្រតិបត្តិការ | ៣ - ៥ |

តម្លៃកាកសំណល់ អាយុកាលប្រើប្រាស់រំពឹងទុក និងវិធីសាស្ត្ររំលស់នៃទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារត្រូវបានត្រួតពិនិត្យឡើងវិញ និងធ្វើនិយ័តកម្មតាមការសមស្របនៅរៀងរាល់ចុងការិយបរិច្ឆេទរាយការណ៍នីមួយៗ។ ផលប៉ះពាល់នឹងត្រូវទទួលស្គាល់ទៅក្នុងរបាយការណ៍ចំណេញ ឬខាតនៅពេលដែលមានការកែសម្រួលកើតឡើង។

### (ឃ) ភតិសន្យា

សិទ្ធិក្នុងការប្រើប្រាស់ទ្រព្យសកម្មត្រូវបានវាស់ដំបូងនៅថ្លៃដើម ដែលរួមមានទឹកប្រាក់ដំបូងនៃបំណុលភតិសន្យាដែលត្រូវបានធ្វើនិយ័តកម្មសម្រាប់ការទូទាត់ភតិសន្យានានា ដែលបានធ្វើឡើងនៅ ឬមុនកាលបរិច្ឆេទចាប់ផ្តើម បូករួមនឹងថ្លៃដើមផ្ទាល់ដំបូងផ្សេងទៀតដែលបានកើតឡើង និងថ្លៃដើមប៉ាន់ស្មានសម្រាប់ការរុះរើ និងដកចេញទ្រព្យសកម្ម ឬស្តារឡើងវិញនូវទ្រព្យសកម្ម ឬទីកន្លែងដែលទ្រព្យសកម្មតាំងនៅ ឬស្តារឡើងវិញនូវទ្រព្យសកម្មទៅតាមលក្ខខណ្ឌនៃភតិសន្យា លើកលែងតែការចំណាយទាំងនោះត្រូវបានកើតឡើងសម្រាប់ការផលិតសន្និធិ ហើយដកការលើកទឹកចិត្តភតិសន្យាដែលបានទទួល។

សិទ្ធិក្នុងការប្រើប្រាស់ទ្រព្យសកម្ម ត្រូវបានរំលស់ជាបន្តបន្ទាប់ដោយប្រើប្រាស់វិធីសាស្ត្ររំលស់ថេរចាប់ពីកាលបរិច្ឆេទចាប់ផ្តើមរហូតដល់ចុងបញ្ចប់នៃរយៈពេលភតិសន្យា លើកលែងតែភតិសន្យាមានការផ្ទេរកម្មសិទ្ធនៃទ្រព្យសកម្មទៅឱ្យក្រុមហ៊ុននៅពេលចប់រយៈពេលភតិសន្យា ឬក៏តម្លៃនៃសិទ្ធិក្នុងការប្រើប្រាស់ទ្រព្យសកម្មឆ្លុះបញ្ចាំងថាក្រុមហ៊ុននឹងអនុវត្តនូវជម្រើសទិញ។ ក្នុងករណីនេះសិទ្ធិក្នុងការប្រើប្រាស់ទ្រព្យសកម្ម នឹងត្រូវរំលស់តាមអាយុកាលប្រើប្រាស់រំពឹងទុក ដែលបានកំណត់ដោយផ្អែកលើមូលដ្ឋានដូចគ្នាទៅនឹងទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ។ បន្ថែមពីនេះទៀត សិទ្ធិក្នុងការប្រើប្រាស់ទ្រព្យសកម្មត្រូវបានកាត់បន្ថយជាទៀងទាត់ ដោយសារឱនភាពនៃតម្លៃខាតបង់បើមាន ហើយត្រូវបានធ្វើនិយ័តកម្មសម្រាប់ការវាស់វែងឡើងវិញនៃបំណុលភតិសន្យា។

# កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ
# សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

## ២. ព័ត៌មានគោលការណ៍គណនេយ្យសំខាន់ៗ (ត)

### (ឃ) ភតិសន្យា (ត)

បំណុលភតិសន្យាត្រូវបានវាស់វែងដំបូងនៅតម្លៃបច្ចុប្បន្ននៃការទូទាត់ភតិសន្យា ដែលមិនទាន់បានបង់នៅកាលបរិច្ឆេទចាប់ផ្តើម ដោយធ្វើអប្បហារប្រើអត្រាការប្រាក់ជាក់ស្តែងចែងនៅក្នុងភតិសន្យា ឬប្រសិនបើ អត្រាការប្រាក់នោះមិនអាចកំណត់បាន ជាទូទៅក្រុមហ៊ុននឹងប្រើអត្រាប្រាក់កម្ចីកើនឡើងរបស់ខ្លួនជា អត្រាអប្បហារ។

ការទូទាត់ភតិសន្យារួមបញ្ចូលក្នុងការវាស់វែងបំណុលភតិសន្យា ត្រូវបានបង្ហាញដូចខាងក្រោម៖

- ការទូទាត់ថេរ រួមទាំងការទូទាត់រូបធាតុថេរ។
- ការទូទាត់ភតិសន្យាអថេរអាស្រ័យលើសន្ទស្សន៍ឬអត្រាណាមួយដែលវាស់វែងដំបូងដោយប្រើ សន្ទស្សន៍ ឬអត្រាមួយនៅកាលបរិច្ឆេទចាប់ផ្តើម។
- ទឹកប្រាក់រំពឹងថានឹងត្រូវបង់ក្រោមការធានាតម្លៃកាកសំណល់ និងតម្លៃអនុវត្តក្រោមជម្រើសនៃការទិញដែលក្រុមហ៊ុនបានអនុវត្តក្នុងហេតុផលសមរម្យ ការបន្តជួលក្នុងរយៈពេលថ្មី ប្រសិនបើក្រុមហ៊ុនមានហេតុផលជាក់លាក់ក្នុងការប្រើជម្រើសពន្យារពេល និងការពិន័យលើការបញ្ចប់ភតិសន្យាលើកលែងតែក្រុមហ៊ុនមានភាពប្រាកដសមហេតុផលថា នឹងមិនបញ្ចប់មុនកាលកំណត់។

**ការជួលរយៈពេលខ្លី និងការជួលទ្រព្យសកម្មដែលមានតម្លៃទាប**

ក្រុមហ៊ុនបានជ្រើសរើសមិនទទួលស្គាល់សិទ្ធិក្នុងការប្រើប្រាស់ទ្រព្យសកម្ម និងបំណុលភតិសន្យាដែលបានជួលក្នុងរយៈពេលខ្លី និងការជួលទ្រព្យសកម្មដែលមានតម្លៃទាប។ ក្រុមហ៊ុនទទួលស្គាល់ភតិសន្យាទាំងនេះ ជាចំណាយដោយផ្អែកលើមូលដ្ឋានថេរក្នុងរយៈពេលភតិសន្យា។

### (ង) សន្និធិ

សន្និធិត្រូវបានយោងនៅតម្លៃទាបជាងរវាងថ្លៃដើម និងតម្លៃពិតប្រាកដ។

ថ្លៃដើមត្រូវបានគណនាដោយប្រើវិធីសាស្ត្រមធ្យមទម្ងន់ ឬវិធីសាស្ត្រកំណត់ជាក់លាក់ណាមួយ ដែលរួមមានរាល់ថ្លៃដើមនៃការទិញ ចំណាយលើការបម្លែង និងថ្លៃដើមផ្សេងទៀតដែលនាំយកសន្និធិទៅទីតាំង និងស្ថានភាពបច្ចុប្បន្នរបស់វា។

នៅពេលសន្និធិត្រូវបានលក់ តម្លៃយោងនៃសន្និធិទាំងនោះត្រូវបានទទួលស្គាល់ជាចំណាយក្នុងការិយបរិច្ឆេទខណៈពេលដែលប្រាក់ចំណូលពាក់ព័ន្ធក៏ត្រូវបានទទួលស្គាល់។ ទឹកប្រាក់សន្និធិលុបចេញពីបញ្ជីទៅតម្លៃពិតប្រាកដ និងការខាតបង់នៃសន្និធិទាំងអស់ត្រូវបានទទួលស្គាល់ជាចំណាយក្នុងការិយបរិច្ឆេទនៃការលុបចេញ ឬការខាតបង់កើតឡើង។ ទឹកប្រាក់នៃការកត់បញ្ច្រាសសន្និធិលុបចេញពីបញ្ជី ត្រូវបានទទួលស្គាល់ជាការកាត់បន្ថយទឹកប្រាក់សន្និធិ ដែលត្រូវបានទទួលស្គាល់ថាជាចំណាយក្នុងការិយបរិច្ឆេទដែលកំណត់បញ្ច្រាសបានកើតឡើង។

## ២. ព័ត៌មានគោលការណ៍គណនេយ្យសំខាន់ៗ(ត)

### (ច) គណនីត្រូវទទួល

គណនីត្រូវទទួល ត្រូវបានទទួលស្គាល់នៅពេលដែលក្រុមហ៊ុនមានសិទ្ធិដោយគ្មានលក្ខខណ្ឌដើម្បីទទួលបានការទូទាត់សង។ សិទ្ធិដើម្បីទទួលបានការទូទាត់សងនឹងគ្មានលក្ខខណ្ឌ ប្រសិនបើការទូទាត់នោះដល់កំណត់ត្រូវសងបន្ទាប់ពីផុតពេលវេលាដែលផ្តល់ឱ្យប៉ុណ្ណោះ។

គណនីត្រូវទទួលត្រូវបានកត់ត្រានៅថ្លៃដើមរំលស់ ដោយប្រើវិធីសាស្រ្តការប្រាក់ប្រសិទ្ធភាពដក នឹងសំវិធានធនសម្រាប់ការបាត់បង់ឥណទាន។

### (ឆ) សាច់ប្រាក់ និងសាច់ប្រាក់សមមូល

សម្រាប់របាយការណ៍លំហូរសាច់ប្រាក់ សាច់ប្រាក់ និងសាច់ប្រាក់សមមូលរួមមានសាច់ប្រាក់នៅធនាគារ និងនៅក្នុងដៃ ការដាក់ប្រាក់ជាមួយធនាគារ និងស្ថាប័នហិរញ្ញវត្ថុផ្សេងទៀត ការវិនិយោគរយៈពេលខ្លី និងមានសន្ទនីយភាពខ្ពស់ ដែលអាចប្តូរបានភ្លាមៗទៅជាសាច់ប្រាក់ហើយដែលអាចប្រឈមនឹងហានិភ័យតិចតួចនៃការផ្លាស់ប្តូរតម្លៃ។

ប្រាក់បញ្ញើមានកាលកំណត់ជាមួយគ្រឹះស្ថានហិរញ្ញវត្ថុ ដែលមានអាជ្ញាប័ណ្ណជាផ្នែកមួយនៃសាច់ប្រាក់ និងសមមូលរបស់ក្រុមហ៊ុន ដោយមិនគិតពីកាលកំណត់របស់វាឡើយ ព្រោះក្រុមហ៊ុនអាចដកបានគ្រប់ពេលនៅពេលដែលធ្វើការជូនដំណឹងដល់ស្ថាប័នហិរញ្ញវត្ថុ ជាមុន ៣០ថ្ងៃ ជាមួយនឹងការប្រាក់ដែលត្រូវក្លាយជាអាសារបង់នៅពេលដកប្រាក់។

### (ជ) ប្រាក់កម្ចីមានការប្រាក់

ប្រាក់កម្ចីមានការប្រាក់ ត្រូវបានទទួលស្គាល់ដំបូងក្នុងតម្លៃសមស្របដកនឹងថ្លៃដើមប្រតិបត្តិការ។ បន្ទាប់ពីទទួលស្គាល់ ប្រាក់កម្ចីមានការប្រាក់ត្រូវបានកត់ត្រានៅថ្លៃដើមរំលស់ ភាពខុសគ្នារវាងចំនួនទឹកប្រាក់ដែលបានកត់ត្រាដំបូង និងតម្លៃរំលស់ត្រូវបានកត់ត្រាក្នុងរបាយការណ៍ចំណេញ ឬខាតជាមួយនឹងការប្រាក់ និងថ្លៃសេវាដែលត្រូវបង់ដោយប្រើវិធីសាស្រ្តការប្រាក់ប្រសិទ្ធភាព។

### (ឈ) ការទទួលស្គាល់ចំណូល

ចំណូល ត្រូវបានទទួលស្គាល់នៅពេលដែលការគ្រប់គ្រងលើផលិតផល ឬសេវាកម្មត្រូវបានផ្ទេរទៅឱ្យអតិថិជនតាមចំនួនទឹកប្រាក់ដែលបានសន្យា នៅពេលដែលក្រុមហ៊ុនត្រូវបានគេរំពឹងថានឹងមានសិទ្ធិ ដោយមិនរាប់បញ្ចូលចំនួនទឹកប្រាក់ដែលប្រមូលបានសម្រាប់ភាគីទីបី។ ព័ត៌មានលម្អិតបន្ថែមទៀត អំពីចំណូលរបស់ក្រុមហ៊ុន និងគោលការណ៍ទទួលស្គាល់មានដូចខាងក្រោមៈ

ចំណូលពីការលក់ទំនិញ ឬសេវាកម្ម ត្រូវបានទទួលស្គាល់នៅពេលដែលទំនិញបានប្រគល់ ឬសិទ្ធិនៃការគ្រប់គ្រងបានផ្ទេរឱ្យទៅអតិថិជន។

## ២. ព័ត៌មានគោលការណ៍គណនេយ្យសំខាន់ៗ (ត)

### (ឈ) ការទទួលស្គាល់ចំណូល (ត)

<u>យានយន្ត គ្រឿងចក្រធុនធ្ងន់ និងគ្រឿងបន្លាស់</u>

កាតព្វកិច្ចអនុវត្តត្រូវបានបំពេញនៅពេលប្រគល់យានយន្ត គ្រឿងចក្រធុនធ្ងន់ និងគ្រឿងបន្លាស់ដែលពាក់ព័ន្ធ។

ការធានាលើសពីការជួសជុលនៃការខូចដែលមាននៅពេលលក់ត្រូវបានផ្តល់ជូនអតិថិជន។ ការធានាសេវាកម្មត្រូវបានរាប់ជាកាតព្វកិច្ចអនុវត្តដាច់ដោយឡែកហើយចំណែកនៃតម្លៃប្រតិបត្តិការត្រូវបានបែងចែក។ កាតព្វកិច្ចអនុវត្តសម្រាប់ការធានាសេវាកម្មគឺត្រូវបានបំពេញក្នុងរយៈពេលពីមួយទៅពីរឆ្នាំ ដោយផ្អែកលើពេលវេលាដែលបានកន្លងផុតទៅ។

<u>សេវាកម្ម</u>

ប្រាក់ចំណូលដែលទាក់ទងនឹងសេវាកម្មឥតគិតថ្លៃដែលអនុវត្តលើយានយន្ត និងគ្រឿងចក្រធុនធ្ងន់ត្រូវបានបំបែកចេញពីប្រាក់ចំណូលនៃទំនិញ ហើយត្រូវបានទទួលស្គាល់នៅពេលដែលសេវាកម្មត្រូវបានបំពេញ។ សម្រាប់សេវាកម្មបង់ថ្លៃផ្សេងទៀតដែលទាក់ទងនឹងយានយន្ត និងគ្រឿងចក្រធុនធ្ងន់ កាតព្វកិច្ចនៃការអនុវត្តត្រូវបានបំពេញតាមពេលវេលាជាក់លាក់មួយដែលសេវាកម្មនេះត្រូវបានបំពេញ ហើយការទូទាត់ជាទូទៅត្រូវកំណត់នៅពេលបញ្ចប់ និងទទួលយកដោយអតិថិជន។

### (ញ) ចំណាយប្រាក់កម្ចី

ចំណាយប្រាក់កម្ចីគឺជាចំណាយក្នុងរយៈពេលដែលបានកើតឡើង លើកលែងតែទំហំដែលត្រូវទទួលស្គាល់ជាទ្រព្យ ដែលកើតឡើងដោយផ្ទាល់ទៅនឹងការទិញយក ការសាងសង់ ឬការផលិតទ្រព្យសកម្មដែលចាំបាច់ត្រូវការរយៈពេលច្រើនដើម្បីរួចរាល់សម្រាប់ការប្រើប្រាស់ដែលបានគ្រោងទុក ឬការលក់។

### (ដ) ប្រតិបត្តិការតាមផ្នែក

ប្រតិបត្តិការតាមផ្នែកត្រូវបានរាយការណ៍តាមរបៀបដែលស្របទៅនឹងរបាយការណ៍ផ្ទៃក្នុង ដែលបានផ្តល់ជូនដល់ប្រធានប្រតិបត្តិការ ដែលជាអ្នកធ្វើការសំរេចចិត្ត។ នាយកប្រតិបត្តិរបស់ក្រុមហ៊ុនដែលទទួលខុសត្រូវក្នុងការបែងចែកធនធាន និងវាយតម្លៃការអនុវត្តន៍នៃប្រតិបត្តិការតាមផ្នែកត្រូវបានគេកំណត់ថាជាប្រធានប្រតិបត្តិការដែលជាអ្នកធ្វើការសំរេចចិត្តលើយុទ្ធសាស្ត្រ។

### (ឋ) ឧបករណ៍ហិរញ្ញវត្ថុ

ចំណាត់ថ្នាក់ និងការវាស់វែងនៃឧបករណ៍ហិរញ្ញវត្ថុ។

ក្រុមហ៊ុនបានចាត់ថ្នាក់ទ្រព្យសកម្មហិរញ្ញវត្ថុជាពីចំណាត់ថ្នាក់ចម្បង៖ វាស់វែងដោយថ្លៃដើមរំលស់ នៅតម្លៃសមស្របតាមរយៈប្រាក់ចំណូលលម្អិតផ្សេងៗ ("FVTOCI")។ ចំណាត់ថ្នាក់នៃទ្រព្យសកម្មហិរញ្ញវត្ថុ គឺពឹងផ្អែកលើគំរូអាជីវកម្មដែលគ្រប់គ្រងដោយទ្រព្យសកម្មហិរញ្ញវត្ថុ និងលក្ខណៈលំហូរសាច់ប្រាក់តាមកិច្ចសន្យា។

មិនមានការផ្លាស់ប្តូរចំណាត់ថ្នាក់ និងការវាស់វែងសម្រាប់បំណុលហិរញ្ញវត្ថុរបស់ក្រុមហ៊ុនឡើយ។

## ៣. ការអនុម័តលើ ស.រ.ទ.ហ.អ.ក ថ្មី និងការធ្វើវិសោធនកម្ម/ការកែសម្រួលនៃ ស.រ.ទ.ហ.អ.ក

### (ក) ការធ្វើវិសោធនកម្ម/ការកែសម្រួលលើស្តង់ដារដែលត្រូវបានអនុម័តនៅក្នុងឆ្នាំ

ការបង្ហាញគោលការណ៍គណនេយ្យ - វិសោធនកម្មចំពោះ ស.គ.អ.ក ១ និង ស.រ.ទ.ហ.អ.ក ការអនុវត្តសេចក្តីថ្លែងការណ៍ទី ២

វិសោធនកម្មតម្រូវឱ្យអង្គភាព បង្ហាញព័ត៌មានអំពីគោលការណ៍គណនេយ្យជាសារវន្តរបស់ខ្លួន ជាជាងគោលការណ៍គណនេយ្យសំខាន់ៗ។ វិសោធនកម្ម ក្នុងចំណោមវិសោធនកម្មផ្សេងទៀត ក៏រួមបញ្ចូលនូវឧទាហរណ៍នៃកាលៈទេសៈដែលអង្គភាពមួយទំនងជា នឹងពិចារណាព័ត៌មានអំពីគោលការណ៍គណនេយ្យដែលមានភាពសារវន្តសម្រាប់របាការណ៍ហិរញ្ញវត្ថុរបស់ខ្លួន។ ដើម្បីគាំទ្រដល់វិសោធនកម្មនេះ ស.រ.ទ.ហ.អ.ក ការអនុវត្តសេចក្តីថ្លែងការណ៍ទី២ក៏ត្រូវបានកែប្រែផងដែរ ដើម្បីផ្តល់ការណែនាំអំពីរបៀបអនុវត្តគំនិតគោលការណ៍គណនេយ្យជាសារវន្ត ព្រមទាំងព័ត៌មានពន្យល់ផ្សេងៗ។ ការណែនាំ និងឧទាហរណ៍ដែលបានផ្តល់នៅក្នុង ស.រ.ទ.ហ.អ.ក ការអនុវត្តសេចក្តីថ្លែងការណ៍ទី ២ បញ្ជាក់ពីតម្រូវការក្នុងការផ្តោតលើព័ត៌មានជាក់លាក់របស់អង្គភាព និងបង្ហាញពីរបៀបដែលដំណើរការសម្ភារៈ ៤ ជំហានអាចដោះស្រាយព័ត៌មានស្តង់ដារ (ឬ boilerplate) និងការចម្លងតម្រូវការនៃ ស.រ.ទ.ហ.អ.ក នៅក្នុងការបង្ហាញគោលការណ៍គណនេយ្យជាសារវន្ត។

ទោះជាយ៉ាងណាក៏ដោយ វិសោធនកម្មនេះមិនមានផលប៉ះពាល់នៅក្នុងការផ្លាស់ប្តូរជាសារវន្តចំពោះគោលការណ៍គណនេយ្យរបស់ក្រុមហ៊ុនទេ។

វិសោធនកម្ម ឬការកែលម្អខាងក្រោមត្រូវបានអនុម័តដោយក្រុមហ៊ុនប៉ុន្តែមិនមានឥទ្ធិពលខ្លាំងលើរយៈពេលបច្ចុប្បន្ន ឬអំឡុងពេលមុនណាមួយឡើយ ហើយវាមិនទំនងជាប៉ះពាល់ដល់រយៈពេលអនាគតទេ។

- និយមន័យនៃការប៉ាន់ស្មានគណនេយ្យ – វិសោធនកម្មចំពោះ ស.គ.អ.ក ៨
- ពន្ធពន្យារដែលទាក់ទងទៅនិង ទ្រព្យសកម្ម និងបំណុលពីប្រតិបត្តិការតែមួយ – វិសោធនកម្មចំពោះ ស.គ.អ.ក ១២

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

### ៣. ការអនុលោមស.រ.ឧ.ហ.អ.ក និងការធ្វើវិសោធនកម្ម ឬកំណែលម្អលើស.រ.ឧ.ហ.អ.ក (ត)

### (ខ) ស្តង់ដារ និងការធ្វើវិសោធនកម្ម ឬកំណែលំអរដែលមិនទាន់អនុលោម

| | | ថ្ងៃចូលជាធរមាន ក្នុងអំឡុង ការិយបរិច្ឆេទចាប់ផ្តើម ឬ ការិយបរិច្ឆេទបន្ទាប់ |
|---|---|---|
| <u>ស្តង់ដារគណនេយ្យថ្មី</u> | | |
| ស.រ.ហ.អ.ក ១៧ | កិច្ចសន្យាធានារ៉ាប់រង | ថ្ងៃទី១ ខែមករា ឆ្នាំ២០២៥ |
| <u>វិសោធនកម្ម ឬការកែសម្រួល</u> | | |
| ស.គ.អ.ក ១ | ការចាត់ថ្នាក់នៃបំណុលរយៈពេលខ្លី ឬបំណុលរយវែង | ថ្ងៃទី១ ខែមករា ឆ្នាំ២០២៤ |
| ស.គ.អ.ក ១ | បំណុលរយៈពេលវែងជាមួយកិច្ចព្រមព្រៀង | ថ្ងៃទី១ ខែមករា ឆ្នាំ២០២៤ |
| ស.រ.ទ.ហ.អ.ក ១៦ | បំណុលភតិសន្យាក្នុងការលក់ និងជួលត្រឡប់ | ថ្ងៃទី១ ខែមករា ឆ្នាំ២០២៤ |
| ស.គ.អ.ក ៧ & ស.រ.ទ.ហ.អ.ក ៧ | ការរៀបចំហិរញ្ញវត្ថុរបស់អ្នកផ្គត់ផ្គង់ | ថ្ងៃទី១ ខែមករា ឆ្នាំ២០២៤ |
| ស.រ.ហ.អ.ក ១៧ | ការអនុវត្តលើកដំបូងនៃស.រ.ហ.អ.ក ១៧ និងស.រ.ហ.អ.ក ៩ - ព័ត៌មានប្រៀបធៀប | ថ្ងៃទី១ ខែមករា ឆ្នាំ២០២៥ |
| ស.រ.ហ.អ.ក ១០ និងស.គ.អ.ក ២៨ | ការលក់ ឬការរួមចំណែកនៃ ទ្រព្យសកម្មរវាង អ្នកវិនិយោគ និង សមាគត ឬការបណ្តាក់ទុនរួមគ្នា | ពន្យារ |

ក្រុមហ៊ុនគ្រោងនឹងអនុម័តវិសោធនកម្មខាងលើចំពោះ ស.រ.ទ.ហ.អ.ក នៅពេលដែលវាមានប្រសិទ្ធិភាព។ ផ្អែកលើការវាយតម្លៃរបស់គណៈគ្រប់គ្រង ស្តង់ដារ វិសោធនកម្ម ឬការបកស្រាយទាំងនេះមិនត្រូវបានគេរំពឹងថានឹងមានផលប៉ះពាល់ជាសារវន្តលើអង្គភាពនៅក្នុងរយៈពេលរាយការណ៍បច្ចុប្បន្ន ឬអនាគត និងលើប្រតិបត្តិការនាពេលអនាគតដែលអាចមើលបាននោះទេ។

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

### ៤. ការប៉ាន់ស្មាន ការសន្មត និងការវិនិច្ឆ័យគណនេយ្យសំខាន់ៗ

ផ្នែកសំខាន់ៗនៃការប៉ាន់ស្មាន ភាពមិនច្បាស់លាស់ និងការវិនិច្ឆ័យសំខាន់ៗ ដើម្បីអនុវត្តតាមគោលការណ៍គណនេយ្យ ដែលមានផលប៉ះពាល់សំខាន់ៗក្នុងការកំណត់តម្លៃបានទទួលស្គាល់ក្នុងរបាយការណ៍ហិរញ្ញវត្ថុរួមមានដូចខាងក្រោមៈ

#### (ក) រំលស់ និងអាយុកាលប្រើប្រាស់របស់ទ្រព្យសម្បត្តិ និងបរិក្ខារ

ដូចមានបង្ហាញក្នុងកំណត់សម្គាល់ ២(គ) ក្រុមហ៊ុនបានពិនិត្យតម្លៃកាកសំណល់ អាយុកាលប្រើប្រាស់ និងវិធីសាស្ត្ររំលស់នៅចុងការិយបរិច្ឆេទរាយការណ៍នីមួយៗ។ ការប៉ាន់ស្មាន ត្រូវបានប្រើប្រាស់ក្នុងការជ្រើសរើសវិធីសាស្ត្ររំលស់ អាយុកាលប្រើប្រាស់ និងតម្លៃកាកសំណល់។ ការប្រើប្រាស់ជាក់ស្តែងនៃអត្ថប្រយោជន៍របស់ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ អាចខុសគ្នាពីការប៉ាន់ស្មាន ដូចនេះការរំលស់នាពេលអនាគតអាចនឹងត្រូវពិនិត្យឡើងវិញ។

តម្លៃយោងរបស់ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខាររបស់ក្រុមហ៊ុន ត្រូវបានបង្ហាញក្នុងកំណត់សម្គាល់ ៥។

#### (ខ) ឱនភាពតម្លៃនៃទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ

ក្រុមហ៊ុនវាយតម្លៃឱនភាពតម្លៃនៃទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុ រាល់ពេលដែលព្រឹត្តិការណ៍ ឬការផ្លាស់ប្តូរកាលៈទេសៈដែលចង្អុលបង្ហាញថាតម្លៃយោងនៃទ្រព្យសកម្មអាចនឹងមិនទទួលបានមកវិញ ឧទាហរណ៍ តម្លៃយោងនៃទ្រព្យសកម្មច្រើនជាងតម្លៃដែលអាចទទួលបានមកវិញ។

តម្លៃដែលអាចទទួលបានមកវិញ ត្រូវបានវាស់នៅតម្លៃខ្ពស់ជាងតម្លៃសមស្របដក ចំណាយការលក់សម្រាប់ទ្រព្យសកម្ម និងតម្លៃក្នុងការប្រើប្រាស់។ តម្លៃក្នុងការប្រើប្រាស់ គឺតម្លៃបច្ចុប្បន្នសុទ្ធនៃលំហូរសាច់ប្រាក់នាពេលអនាគតដែលត្រូវបានរំពឹងថានឹងទទួលបានពីទ្រព្យសកម្មនោះ ដោយធ្វើអប្បហារនៅអត្រាការប្រាក់អប្បហារសមស្រប។ ក្រុមហ៊ុនប្រើការវិនិច្ឆ័យដើម្បីកំណត់អត្រាអប្បហារក្នុងការគណនាតម្លៃដែលអាចទទួលបានមកវិញនិងការសន្មតការព្យាករណ៍លំហូរសាច់ប្រាក់ រួមទាំងអត្រាកំណើនព្យាករណ៍ អត្រាអតិផរណា និងប្រាក់ចំណេញដុល។ លំហូរសាច់ប្រាក់ព្យាករណ៍ផ្អែកលើធាតុចូល ឬការសន្មត ដែលអាចជះឥទ្ធិពលយ៉ាងខ្លាំងដល់ស្ថានភាពនិងលទ្ធផលហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ប្រសិនបើលំហូរសាច់ប្រាក់ជាក់ស្តែងតិចជាងការរំពឹងទុក។

តម្លៃយោងទ្រព្យសកម្មមិនមែនហិរញ្ញវត្ថុត្រូវបានបង្ហាញនៅក្នុងកំណត់សម្គាល់ ៥ និង ៦ ។

#### (គ) ការលុបចោលសន្និធិដែលហួសសម័យ ឬសន្និធិដែលយឺតយ៉ាវ

ក្រុមហ៊ុនលុបចោលសន្និធិដែលហួសសម័យ ឬសន្និធិដែលយឺតយ៉ាវ ដោយផ្អែកលើការវាយតម្លៃនៃការប៉ាន់ស្មានថ្លៃលក់ពិតរបស់សន្និធិនោះ។ សន្និធិដែលត្រូវបានលុបចោលនៅពេលដែលមានព្រឹត្តិការណ៍ ឬការផ្លាស់ប្តូរក្នុងស្ថានភាពដែលចង្អុលបង្ហាញថា តម្លៃយោងនឹងមិនអាចទទួលបានមកវិញ។ គណៈគ្រប់គ្រងវិភាគនិន្នាការលក់ និងស្ថានភាពសេដ្ឋកិច្ចបច្ចុប្បន្ន នៅពេលធ្វើការវិនិច្ឆ័យដើម្បីវាយតម្លៃការលុបចោលសន្និធិដែលហួសសម័យ ឬសន្និធិយឺតយ៉ាវ។ នៅពេលដែលការរំពឹងទុកខុសពីការប៉ាន់ស្មានដំបូង ភាពខុសគ្នានោះ នឹងប៉ះពាល់ដល់តម្លៃយោងរបស់សន្និធិ។

តម្លៃយោងសន្និធិរបស់ក្រុមហ៊ុនត្រូវបានបង្ហាញក្នុងកំណត់សម្គាល់ ៩។

## ៤. ការប៉ាន់ស្មាន ការសន្មត និងការវិនិច្ឆ័យគណនេយ្យសំខាន់ៗ (ត)

### (ឃ) ឱនភាពតម្លៃនៃគណនីអតិថិជនពាណិជ្ជ

សំវិធានធននៃឱនភាពតម្លៃនៃគណនីអតិថិជនពាណិជ្ជ ត្រូវពឹងផ្អែកលើការសន្មត់អំពីហានិភ័យអត្រាការប្រាក់ និងការខាតបង់អត្រាការប្រាក់រំពឹងទុក។ ក្រុមហ៊ុនប្រើការវិនិច្ឆ័យដើម្បីធ្វើការសន្មតទាំងនេះ និងការជ្រើសរើសធាតុចូលទៅគណនាឱនភាពនៃតម្លៃដោយផ្អែកលើប្រវត្តិក្រុមហ៊ុនកាលពីមុន លក្ខខណ្ឌស្ថានភាពទីផ្សារដែលមានស្រាប់ក៏ដូចជាការប៉ាន់ស្មានទៅមុខនៅចុងបញ្ចប់ការិយ បរិច្ឆេទរាយការណ៍នីមួយៗ។

ក្រុមហ៊ុនប្រើម៉ាទ្រីសសំវិធានធនដើម្បីគណនាការបាត់បង់ឥណទានរំពឹងទុកសម្រាប់គណនីអតិថិជនពាណិជ្ជកម្ម និងគណនីត្រូវទទួលផ្សេងៗ និងទ្រព្យសកម្មកិច្ចសន្យា។ អត្រាសំវិធានធនគឺអាស្រ័យលើចំនួនថ្ងៃដែលគណនីអតិថិជនពាណិជ្ជកម្មបានហួសកំណត់។ ក្រុមហ៊ុនធ្វើការចែកជាក្រុមចំពោះអតិថិជនដែលមានលំនាំបាត់បង់ស្រដៀងគ្នា។ លក្ខណៈវិនិច្ឆ័យរួមមានតំបន់ភូមិសាស្ត្រ ប្រភេទផលិតផល ប្រភេទអតិថិជន និងចំណាត់ថ្នាក់ទ្រព្យបញ្ចាំ ឬការធានារ៉ាប់រងឥណទានពាណិជ្ជកម្ម។

ម៉ាទ្រីសនៃការផ្តល់ត្រូវបានផ្អែកដំបូងតាមអត្រាខាតបង់ ដែលអាចសង្កេតឃើញកន្លងមករបស់ក្រុមហ៊ុន។ ក្រុមហ៊ុននឹងក្រិតតាមខ្នាតម៉ាទ្រីស ដើម្បីកែសម្រួលបទពិសោធកន្លងមកនៃការបាត់បង់ឥណទាន ជាមួយនឹងព័ត៌មានឆ្ពោះទៅមុខ។ នៅរៀងរាល់កាលបរិច្ឆេទរាយការណ៍ អត្រាការប្រាក់ខាតបង់ដែលបានសង្កេតឃើញកន្លងមក ត្រូវបានធ្វើបច្ចុប្បន្នភាព ហើយការផ្លាស់ប្តូរការប៉ាន់ស្មានសម្លឹងទៅមុខត្រូវបានវិភាគ។

ការវាយតម្លៃលើទំនាក់ទំនងរវាងអត្រាការប្រាក់ខាតបង់ដែលអាចសង្កេតឃើញកន្លងមក ការប៉ាន់ស្មានទៅមុខ និងការខាតបង់ឥណទានរំពឹងទុកគឺជាការប៉ាន់ស្មានដ៏សំខាន់មួយ។ ចំនួនទឹកប្រាក់នៃការបាត់បង់ឥណទានរំពឹងទុកគឺមានផលប៉ះពាល់ចំពោះការផ្លាស់ប្តូរកាលៈទេសៈ និងការព្យាករណ៍លក្ខខណ្ឌសេដ្ឋកិច្ចលើអាយុកាលរំពឹងទុកនៃទ្រព្យសកម្មហិរញ្ញវត្ថុ និងទ្រព្យសកម្មកិច្ចសន្យា។ បទពិសោធន៍កន្លងមកលើការបាត់បង់ឥណទានរបស់ក្រុមហ៊ុន និងការព្យាករណ៍អំពីស្ថានភាពសេដ្ឋកិច្ចក៏អាចមិនតំណាងឱ្យភាពមិនពិតប្រាកដរបស់អតិថិជននាពេលអនាគតនោះទេ។

ព័ត៌មានអំពីការខាតបង់លើឱនភាពតម្លៃនៃគណនីអតិថិជនពាណិជ្ជ របស់ក្រុមហ៊ុនត្រូវបានបង្ហាញនៅកំណត់សម្គាល់ ១០។

### (ង) ការវាស់វែងពន្ធលើប្រាក់ចំណូល

ការវិនិច្ឆ័យសំខាន់គឺចាំបាច់ក្នុងការកំណត់ការប៉ាន់ប្រមាណរបស់ក្រុមហ៊ុនចំពោះពន្ធក្នុងគ្រា និងពន្ធពន្យារ ព្រោះបំណុលពន្ធចុងក្រោយរបស់ក្រុមហ៊ុនទាំងមូលមិនមានភាពច្បាស់លាស់។ នៅពេលលទ្ធផលចុងក្រោយនៃប្រាក់ពន្ធដែលត្រូវបង់ ត្រូវបានកំណត់ដោយអាជ្ញាធរពន្ធដារក្នុងយុត្តាធិការនីមួយៗ ទឹកប្រាក់បង់ពន្ធនេះអាចខុសគ្នាពីការប៉ាន់ស្មានដំបូងនៃប្រាក់ពន្ធដែលត្រូវបង់។ ភាពខុសគ្នានេះអាចប៉ះពាល់ដល់ពន្ធក្នុងគ្រា និងពន្ធពន្យារក្នុងគ្រាដែលបានកំណត់។ ក្រុមហ៊ុននឹងធ្វើនិយ័តកម្មពន្ធក្នុងគ្រា ឬពន្ធពន្យារពីឆ្នាំមុនក្នុងគ្រាបច្ចុប្បន្នលើភាពខុសគ្នាទាំងនោះ។

ចំណាយពន្ធលើប្រាក់ចំណូលរបស់ក្រុមហ៊ុនត្រូវបានបង្ហាញនៅក្នុងកំណត់សម្គាល់ ២២។

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

### ៤. ការប៉ាន់ស្មាន ការសន្មត និងការវិនិច្ឆ័យគណនេយ្យសំខាន់ៗ (ត)

### (ច) បំណុលជាយថាហេតុ

ក្រុមហ៊ុនអនុវត្តការវិនិច្ឆ័យក្នុងការវាស់វែង និងការទទួលស្គាល់សំវិធានធន និងការប្រឈមការប៉ះពាល់ទៅនឹងបំណុលជាយថាហេតុដែលជាប់ទាក់ទងនឹងវិវាទដែលមិនទាន់សម្រេច ឬការទាមទារសំណងផ្សេងទៀតដែលស្ថិតក្រោមការដោះស្រាយវិវាទដោយចរចារ ឬអាជ្ញាកណ្តាល ឬបទប្បញ្ញត្តិរបស់រដ្ឋាភិបាល។ ការវិនិច្ឆ័យត្រូវបានទាមទារដើម្បីវាយតម្លៃលទ្ធភាពដែលការទាមទារដែលមិនទាន់សម្រេច នឹងទទួលបានជោគជ័យ ឬបំណុលនឹងកើតឡើងហើយកំណត់បរិមាណ ដែលអាចកើតមាននៃដំណោះស្រាយហិរញ្ញវត្ថុណាមួយ។ ភាពមិនប្រាកដប្រជានៃបញ្ហាបែបនេះ មានន័យថាការខាតបង់ជាក់ស្តែងអាចមានលក្ខណៈខុសគ្នាពីការប៉ាន់ស្មាន។

# កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ
# សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

## ៥. ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ

| | អាគារ<br>ដុល្លារអាមេរិក | បរិក្ខារសេវាកម្ម និង បរិក្ខារឃ្លាំង<br>ដុល្លារអាមេរិក | គ្រឿងសង្ហារឹម និងបរិក្ខារបំពាក់<br>ដុល្លារអាមេរិក | ការកែលម្អដីធ្លី<br>ដុល្លារអាមេរិក | យានយន្ត<br>ដុល្លារអាមេរិក | បរិក្ខារសម្រាប់ ប្រតិបត្តិការ<br>ដុល្លារអាមេរិក | ទ្រព្យសកម្ម កំពុងសាងសង់<br>ដុល្លារអាមេរិក | សរុប<br>ដុល្លារអាមេរិក |
|---|---|---|---|---|---|---|---|---|
| ថ្លៃដើម | | | | | | | | |
| **នាថ្ងៃទី១ ខែមករា ឆ្នាំ២០២២** | ៥.៧៤២.៦១១ | ១.៤៤១.៦៦០ | ១.០២២.៩១៥ | ១.១៧៤.៨៧២ | ៧.៧៨៥.៣៣១ | ៣.០៣០.៥៨៧ | ៦៥៤.១៤៧ | ២០.៨៥២.១២៣ |
| ការទិញបន្ថែម | ៦៦០.៣១២ | ១៦៨.០១៦ | ២៧.៨២២ | ២៤២.៣០១ | - | ៦៥៥.៨៧៤ | ១.៧៨៧.៨៦៣ | ៣.៥៤២.១៨៨ |
| ការផ្ទេរពីសន្និធិ (កំណត់សម្គាល់៩) | - | ៧.០០០ | - | - | ៥.១១៧.៧១២ | ៣៥១.៤៦១ | - | ៥.៤៧៦.១៧៣ |
| ការលក់ | - | (២.៤០០) | (៦២២) | - | (៨៣៨.២៥៦) | (២០៧.១៧៤) | (៤.៦៧០) | (១.០៥៣.១២២) |
| លុបចោល | (១៥៣.៥៧១) | (១.៧០០) | (៦.៧៧១) | (៣៥.៧៤៥) | - | (៤០.០៣៧) | - | (២៣៧.៨២៤) |
| ការផ្ទេរទៅសន្និធិ (កំណត់សម្គាល់៩) | - | (២.២៧៥) | - | - | (២.៥៦៦.៧០៣) | (៣៩៨.០៣៧) | - | (២.៩៦៧.០១៥) |
| ការផ្ទេរពីទ្រព្យសកម្មកំពុងសាងសង់ | ៥៦១.៣១៩ | - | - | ៣៩.៥៩៨ | - | ៦.៦៦៧ | (៦០៧.៥៨៤) | - |
| **នាថ្ងៃទី៣១ ខែធ្នូឆ្នាំ២០២២/ ១ ខែមករា ឆ្នាំ២០២៣** | ៦.៨១០.៦៧១ | ១.៦១០.៣០១ | ១.០៤៣.៣៤៤ | ១.៤២១.០២៦ | ៩.៤៩៨.០៨៤ | ៣.៣៩៩.៣៤១ | ១.៨២៩.៧៥៦ | ២៥.៦១២.៥២៣ |
| ការទិញបន្ថែម | ២.០១១.៥២០ | ៧៦៣.៣៥១ | ១៦៤.៦១៦ | ៤៩៨.៧៧៩ | - | ៩៦១.៥៣៧ | ១.៨៦២.៣៨០ | ៦.២៦២.១៨៣ |
| ការផ្ទេរពីសន្និធិ (កំណត់សម្គាល់៩) | - | - | - | - | ៧.៩៦៨.១៧៥ | ៤៣៧.៧១៨ | - | ៨.៤០៥.៨៩៣ |
| ការលក់ | (៣៣៣.៥៦៣) | - | - | - | (២.៧០១.៣០៣) | (២១.៩៤៨) | - | (៣.០៥៦.៨១៤) |
| លុបចោល | - | - | - | - | - | (៣.១៧០) | - | (៣.១៧០) |
| ការផ្ទេរទៅសន្និធិ (កំណត់សម្គាល់៩) | - | - | - | - | (៤.២៤៤.៦៨២) | (៧១៨.១០៣) | - | (៤.៩៦២.៧៨៥) |
| ការផ្ទេរពីទ្រព្យសកម្មកំពុងសាងសង់ | ១.៦៥១.៥៣៣ | - | - | ៤៦.៧៤៩ | - | ៤.៦៨០ | (១.៧០២.៩៦២) | - |
| **នាថ្ងៃទី៣១ ខែធ្នូឆ្នាំ២០២៣** | ១០.១៤០.១៦១ | ២.៣៧៣.៦៥២ | ១.២០៧.៩៦០ | ១.៩៦៦.៥៥៤ | ១០.៥២០.២៧៤ | ៤.០៦០.០៥៥ | ១.៩៨៩.១៧៤ | ៣២.២៥៧.៨៣០ |

# កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ
### (ក) សមតុល្យពាក់ព័ន្ធសំខាន់ៗ និងប្រតិបត្តិការ

ព័ត៌មានទាក់ទងនឹងសមតុល្យរបស់សម្ព័ន្ធញាតិ ត្រូវបានបង្ហាញក្នុងកំណត់សម្គាល់លេខ ១០ ១១ និង១៥។ ប្រតិបត្តិការរបស់សម្ព័ន្ធញាតិ ក្រៅពីបង្ហាញនៅកន្លែងផ្សេងនៅក្នុងរបាយការណ៍ហិរញ្ញវត្ថុមានដូចខាងក្រោម៖

| | ២០២៣ | | ២០២២ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| **ជាមួយក្រុមហ៊ុនកាន់កាប់ផ្ទាល់** | | | | |
| ភាគលាភ | ៩.៩៣៥.៨៤៥ | ៤០.៨៣៦.៣២៣ | ២៣.៣៨៨.៥៦១ | ៩៥.៥៨៩.០៤៩ |
| **ជាមួយម្ចាស់ភាគហ៊ុន** ភាគលាភ | ៩.៩៤៦ | ៤០.៨៧៨ | ២៣.៤១២ | ៩៥.៦៨៥ |
| **ជាមួយភាហ៊ុនិក** | | | | |
| ថ្លៃសេវាគ្រប់គ្រងនិងការបង់ថ្លៃសេវាទៅ | (៣០៥.៧៧៩) | (១.២៥៦.៧៥២) | - | - |
| ការទិញទំនិញ និងសេវាកម្ម | ១៣៣.៨៥៦.៣២៤ | ៥៥០.១៤៩.៤៩២ | ២៩.៨១១.៥១៨ | ១២១.៨៣៩.៦៧៤ |
| ការទិញទ្រព្យសកម្ម | - | - | ១៧.៧៧២ | ៧២.៦៣៤ |
| ការលក់ទំនិញ និងសេវាកម្ម | (២៣៣.៣៣៤) | (៩៥៩.០០៣) | (៨១.៦៩១) | (៣៣៣.៨៧២) |
| ប្រាក់ពិន័យ | ៣.៤០៥.៤២២ | ១៣.៩៩៦.២៨៤ | - | - |
| ការទិញវិនិយោគជាមួយភាហ៊ុនិក | - | - | ២៥០.០០០ | ១.០២១.៧៥០ |
| **ជាមួយបុត្រសម្ព័ន្ធក្រោមក្រុមហ៊ុនមេរួម និងភាគីពាក់ព័ន្ធផ្សេងៗ** | | | | |
| ចំណាយថ្លៃជួលពី | ៨៤៥.២៥០ | ៣.៤៧៣.៩៧៨ | ៩.០០០ | ៣៦.៧៨៣ |
| ចំណាយថ្លៃជួលទៅ | (៩៣.៧០៣) | (៣៨៥.១១៩) | (៣៧.៨០០) | (១៥៤.៤៨៩) |
| ថ្លៃសេវាគ្រប់គ្រង និងការបង់ថ្លៃសេវាពី | ២.៦៣១.៨២៤ | ១០.៨១៦.៧៨៧ | ១.៦៨១.៨២២ | ៦.៨៧៣.៦០៧ |
| ថ្លៃសេវាគ្រប់គ្រង និងការបង់ថ្លៃសេវាទៅ | (៣៥២.៦៥០) | (១.៤៤៩.៣៩២) | (១៦១.០១៧) | (៦៥៨.០៧៦) |
| ការទិញទ្រព្យសកម្ម | ១.៥៨៥.៨២៥ | ៦.៥១៧.៧៤១ | ៣៤៦.៩១៨ | ១.៤១៧.៨៥៤ |
| ការទិញទំនិញ និងសេវាកម្ម | ៥.៨០០.៨៤០ | ២៣.៨៤១.៤៥២ | ៧.៨៩៦.៤៣៣ | ៣២.២៧២.៧២២ |
| ការលក់ទ្រព្យសកម្ម | (១០០.៣៦៣) | (៤១២.៤៩២) | (៤៥.៤៩៥) | (១៨៥.៩៣៨) |
| ការលក់ទំនិញ និងសេវាកម្ម | (៣៨.៣៨៩.៧៣២) | (១៥៧.៧៨១.៧៩៨) | (៦៣.៦០០.៥៣១) | (២៥៩.៩៣៥.៣៧០) |
| ការទិញការវិនិយោគផ្សេងៗ | - | - | ៦០០.០០០ | ២.៤៥២.២០០ |
| ចំណូលពីភាគលាភ | - | - | (៥០០.១២០) | (២.០៤៣.៩៩០) |
| ការប្រាក់បានបង់ | ១៦៩.៩៦០ | ៦៩៨.៥៣៦ | - | - |
| កម្រៃជើងសារ | (៣៦.៧០២) | (១៥០.៨៤៥) | (៩.៦៦០) | (៣៩.៤៨០) |

# កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ
# សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

## ២៥. ប្រតិបត្តិការជាមួយភាគីពាក់ព័ន្ធ (ត)

### (ខ) លាភការសម្រាប់គណៈគ្រប់គ្រងសំខាន់ៗ

គណៈគ្រប់គ្រងសំខាន់ៗរបស់ក្រុមហ៊ុនសំដៅទៅលើអភិបាលក្រុមហ៊ុន និងថ្នាក់ដឹកនាំជាន់ខ្ពស់មួយចំនួន ដែលមានសិទ្ធិអំណាច និងការទទួលខុសត្រូវសម្រាប់ការធ្វើផែនការ ការដឹកនាំ និងការគ្រប់គ្រងសកម្មភាពរបស់ក្រុមហ៊ុនដោយផ្ទាល់ និងដោយប្រយោល។ លាភការសម្រាប់គណៈគ្រប់គ្រងសំខាន់ៗសរុបត្រូវបានវិភាគដូចខាងក្រោម៖

| | ២០២៣ | | ២០២២ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| បៀវត្ស និងប្រាក់ខែ | ២.០៤៦.៦៣៩ | ៨.៤១១.៦៨៦ | ១.៥៧១.៥៨៥ | ៦.៤២៣.០៦៨ |
| កម្រៃក្រុមនាយក | ១៤៤.៨៥២ | ៥៩៥.៣៤២ | ១៣៧.៨៨២ | ៥៦៣.៥២៤ |
| អត្ថប្រយោជន៍ផ្សេងៗ | ១៣៥.១៧៥ | ៥៥៥.៥៦៩ | ១៣៦.០៧០ | ៥៥៦.១១៨ |
| | ២.៣២៦.៦៦៦ | ៩.៥៦២.៥៩៧ | ១.៨៤៥.៥៣៧ | ៧.៥៤២.៧១០ |

## ២៦. ឧបករណ៍ហិរញ្ញវត្ថុ

<u>ប្រភេទនៃឧបករណ៍ហិរញ្ញវត្ថុ</u>

តារាងខាងក្រោមវិភាគពីឧបករណ៍ហិរញ្ញវត្ថុនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុតាមចំណាត់ថ្នាក់នៃឧបករណ៍ហិរញ្ញវត្ថុដែលបានបែងចែក៖

(i) ថ្លៃដើមរំលស់

(ii) កំណត់នៅតម្លៃសមស្របតាមរយៈលទ្ធផលលម្អិតផ្សេងៗ ("FVTOCI")

| | តម្លៃយោង | | ថ្លៃដើមរំលស់ | FVTOCI |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ដុល្លារអាមេរិក |
| **នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣** | | | | |
| **ទ្រព្យសកម្មហិរញ្ញវត្ថុ** | | | | |
| ការវិនិយោគផ្សេងៗ | ៥.៦០០.០០០ | ២២.៨៧៦.០០០ | - | ៥.៦០០.០០០ |
| គណនីអតិថិជនពាណិជ្ជកម្ម | | | | |
| និងគណនីត្រូវទទួលផ្សេងៗ | ១១.៥៧១.៦៣០ | ៤៧.២៧០.១០៨ | ១១.៥៧១.៦៣០ | - |
| ទឹកប្រាក់ជំពាក់ពីភាគីពាក់ព័ន្ធ | ៦.០៨៩.៥០១ | ២៤.៨៧៥.៦១២ | ៦.០៨៩.៥០១ | - |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូល | ២២.១៦២.៦០៥ | ៩០.៥៣៤.២៤១ | ២២.១៦២.៦០៥ | - |
| | ៤៥.៤២៣.៧៣៦ | ១៨៥.៥៥៥.៩៦១ | ៣៩.៨២៣.៧៣៦ | ៥.៦០០.០០០ |

# កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ
# សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

## ២៦. ឧបករណ៍ហិរញ្ញវត្ថុ (ត)

<u>ប្រភេទនៃឧបករណ៍ហិរញ្ញវត្ថុ (ត)</u>

| | តម្លៃយោង | | ថ្លៃដើមរំលស់ | DFVTOCI |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ដុល្លារអាមេរិក |
| **បំណុលហិរញ្ញវត្ថុ** | | | | |
| គណនីត្រូវទូទាត់ពាណិជ្ជកម្ម | | | | |
| និងគណនីត្រូវទូទាត់ផ្សេងៗ | ៨.៥០៤.៩១៧ | ៣៤.៧៤២.៥៨៦ | ៨.៥០៤.៩១៧ | - |
| ទឹកប្រាក់ជំពាក់ទៅភាគីពាក់ព័ន្ធ | ២២.៨២៥.៨១១ | ៩៣.២៤៣.៤៣៨ | ២២.៨២៥.៨១១ | - |
| ឥណទាន និងប្រាក់កម្ចី | ៧៧.៣៣៣.៤០៧ | ៣១៥.៩០៦.៩៦៨ | ៧៧.៣៣៣.៤០៧ | - |
| បំណុលភតិសន្យា | ២៧.៦៧៩.៣០៨ | ១១៣.០៦៩.៩៧៣ | ២៧.៦៧៩.៣០៨ | - |
| | ១៣៦.៣៤៣.៤៤៣ | ៥៥៦.៩៦២.៩៦៥ | ១៣៦.៣៤៣.៤៤៣ | - |
| **នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២** | | | | |
| **ទ្រព្យសកម្មហិរញ្ញវត្ថុ** | | | | |
| ការវិនិយោគផ្សេងៗ | ៥.៦០០.០០០ | ២៣.០៥៥.២០០ | - | ៥.៦០០.០០០ |
| គណនីអតិថិជនពាណិជ្ជ | | | | |
| និងគណនីត្រូវទទួលផ្សេងៗ | ៥.៤៤៩.៨២២ | ២២.៤៣៦.៩១៧ | ៥.៤៤៩.៨២២ | - |
| ទឹកប្រាក់ជំពាក់ពីភាគីពាក់ព័ន្ធ | ៦.៤៦៤.៩០៣ | ២៦.៦១៦.០០៦ | ៦.៤៦៤.៩០៣ | - |
| សាច់ប្រាក់ និងសាច់ប្រាក់សមមូល | ៤២.០៨៤.៣៦៤ | ១៧៣.២៦១.៣២៧ | ៤២.០៨៤.៣៦៤ | - |
| | ៥៩.៥៩៩.០៨៩ | ២៤៥.៣៦៩.៤៥០ | ៥៣.៩៩៩.០៨៩ | ៥.៦០០.០០០ |
| **បំណុលហិរញ្ញវត្ថុ** | | | | |
| គណនីត្រូវទូទាត់ពាណិជ្ជកម្ម | | | | |
| និងគណនីត្រូវទូទាត់ផ្សេងៗ | ៩.៦៦៨.០០៥ | ៣៩.៨០៣.១៧៦ | ៩.៦៦៨.០០៥ | - |
| ទឹកប្រាក់ជំពាក់ទៅភាគីពាក់ព័ន្ធ | ១៥.៧៧០.៣៧៥ | ៦៤.៩២៦.៦៣៤ | ១៥.៧៧០.៣៧៥ | - |
| ឥណទាន និងប្រាក់កម្ចី | ៥៣.៦៤៣.៨១៥ | ២២០.៨៥១.៥៨៥ | ៥៣.៦៤៣.៨១៥ | - |
| បំណុលភតិសន្យា | ៣.៥៥៧.២៣៣ | ១៤.៦៤៥.១២៨ | ៣.៥៥៧.២៣៣ | - |
| | ៨២.៦៣៩.៤២៨ | ៣៤០.២២៦.៥២៣ | ៨២.៦៣៩.៤២៨ | - |

<u>**ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុ**</u>

សកម្មភាពអាជីវកម្មរបស់ក្រុមហ៊ុនត្រូវបានប្រឈមនឹងហានិភ័យហិរញ្ញវត្ថុជាច្រើន ដែលកើតឡើងពីប្រតិបត្តិការរបស់ខ្លួន និងការប្រើប្រាស់ឧបករណ៍ហិរញ្ញវត្ថុ។ ហានិភ័យហិរញ្ញវត្ថុសំខាន់ៗ រួមមានហានិភ័យឥណទាន ហានិភ័យសាច់ប្រាក់ងាយស្រួល ហានិភ័យអត្រាការប្រាក់ និងហានិភ័យរូបិយប័ណ្ណបរទេស។ គោលបំណងនៃការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុទូទៅរបស់ក្រុមហ៊ុន គឺដើម្បីធានាបានថាក្រុមហ៊ុននឹងបង្កើនតម្លៃដល់ម្ចាស់ភាគហ៊ុនរបស់ពួកគេ។ ការគ្រប់គ្រងហានិភ័យហិរញ្ញវត្ថុត្រូវបានអនុវត្តទៅតាមរយៈការពិនិត្យហានិភ័យប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង និងការប្រកាន់ខ្ជាប់នូវគោលការណ៍គ្រប់គ្រងហានិភ័យហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។

# កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ
# សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

## ២៦. ឧបករណ៍ហិរញ្ញវត្ថុ (ត)

### (ក) ហានិភ័យឥណទាន

ហានិភ័យឥណទាន គឺជាហានិភ័យនៃការខាតបង់ហិរញ្ញវត្ថុដល់ក្រុមហ៊ុន ដែលអាចកើតមានឡើងលើឧបករណ៍ហិរញ្ញវត្ថុដែលមិនទាន់បានទូទាត់ក្នុងករណីភាគីអ្នកជំពាក់មិនសងបំណុល។ ក្រុមហ៊ុននឹងត្រូវប្រឈមនឹងហានិភ័យឥណទានពីសកម្មភាពប្រតិបត្តិការរបស់ខ្លួន (ជាចម្បងលើគណនីអតិថិជនពាណិជ្ជកម្ម ទឹកប្រាក់ជំពាក់ពីក្រុមហ៊ុនពាក់ព័ន្ធ និងគណនីទទួលផ្សេងៗ) និងពីសកម្មភាពហិរញ្ញប្បទានរបស់ខ្លួន រួមទាំងប្រាក់បញ្ញើជាមួយធនាគារមានអាជ្ញាប័ណ្ណ។ ក្រុមហ៊ុនមានគោលការណ៍ឥណទានដែលហានិភ័យឥណទានត្រូវបានគ្រប់គ្រងតាមរយៈការអនុវត្តការអនុម័តឥណទាន ដែនកំណត់ឥណទាន និងនីតិវិធីត្រួតពិនិត្យ។ គុណភាពឥណទានរបស់អតិថិជនត្រូវបានវាយតម្លៃដោយផ្អែកលើតារាងពិន្ទុអត្រាឥណទានបន្ថែម ហើយការកំណត់ដែនកំណត់ឥណទានរបស់បុគ្គលម្នាក់ៗត្រូវបានកំណត់ស្របតាមការវាយតម្លៃនេះ។

**គណនីអតិថិជនពាណិជ្ជ**

នាចុងគ្រារាយការណ៍ ការប៉ះពាល់ជាអតិបរមានៃហានិភ័យឥណទានត្រូវបានកើតឡើងពីគណនីអតិថិជនពាណិជ្ជកម្ម ត្រូវបានបង្ហាញនៅតម្លៃយោងនៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។

តម្លៃយោងនៃគណនីអតិថិជនពាណិជ្ជ មិនត្រូវបានដាក់ធានាដោយទ្រព្យបញ្ចាំ ឬការគាំទ្រដោយការពង្រឹងឥណទានណាមួយឡើយ។ ក្នុងការកំណត់លទ្ធភាពដែលអាចប្រមូលបានមកវិញ នៃគណនីត្រូវទទួលទាំងនេះ ក្រុមហ៊ុនធ្វើការពិចារណាលើការផ្លាស់ប្តូរគុណភាពឥណទានណាមួយ នៃគណនីត្រូវទទួលចាប់តាំងពីថ្ងៃដែលឥណទានត្រូវបានផ្តល់ជូនរហូតដល់កាលបរិច្ឆេទរាយការណ៍។ ក្រុមហ៊ុនបានអនុវត្តគោលការណ៍ដោះស្រាយជាមួយសមភាគីដែលអាចជឿជាក់បាន ដែលជាមធ្យោបាយកាត់បន្ថយហានិភ័យពីការបាត់បង់ផ្នែកហិរញ្ញវត្ថុ។

ក្រុមហ៊ុនបានអនុវត្តវិធីសាស្ត្រសាមញ្ញក្នុងការផ្តល់នូវការបាត់បង់ការថយចុះតម្លៃ ដោយ ស.រ.ទ.ហ.អ.ក ៩ ដែលអនុញ្ញាតឱ្យប្រើប្រាស់ការផ្តល់ការបាត់បង់ឥណទាន ដែលរំពឹងទុកជារៀងរហូតសម្រាប់កូនបំណុលពាណិជ្ជកម្ម។ ដើម្បីវាស់ស្ទង់ភាពអន់ថយនៃការបាត់បង់ពាណិជ្ជកម្មដែលបានទទួល ត្រូវបានដាក់ជាក្រុមដោយផ្អែកលើលក្ខណៈហានិភ័យនៃភាគហ៊ុនឥណទាន និងថ្ងៃផុតកំណត់។ ការខាតបង់លើការចុះខ្សោយក៏រួមបញ្ចូលព័ត៌មានដែលមើលទៅខាងមុខផងដែរ។ ទោះយ៉ាងណាក៏ដោយ ដោយផ្អែកលើការវាយតម្លៃដែលធ្វើឡើងដោយអ្នកគ្រប់គ្រង ការខាតបង់ដែលត្រូវបានកំណត់អត្តសញ្ញាណគឺមិនមែនជាសារវន្តទេ។

# កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ
# សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

## ២៦. ឧបករណ៍ហិរញ្ញវត្ថុ (ត)

### (ក) ហានិភ័យឥណទាន (ត)

#### គណនីត្រូវទទួល និងទ្រព្យសកម្មហិរញ្ញវត្ថុផ្សេងៗ

ចំពោះគណនីត្រូវទទួល និងទ្រព្យសកម្មហិរញ្ញវត្ថុផ្សេងៗ (រាប់បញ្ចូលទាំងប្រាក់បញ្ញើនៅធនាគារ និងស្ថាប័នហិរញ្ញវត្ថុ) ក្រុមហ៊ុនធ្វើការកាត់បន្ថយហានិភ័យឥណទាន ដោយដោះស្រាយផ្ទាល់មុខជាមួយសមភាគីចំពោះឥណទានណាដែលមានចំណាត់ថ្នាក់ខ្ពស់។ នាកាលបរិច្ឆេទរាយការណ៍ ការប៉ះពាល់ជាអតិបរមារបស់ក្រុមហ៊ុនចំពោះហានិភ័យឥណទានដែលកើតឡើងពីគណនីត្រូវទទួលផ្សេងៗ ទឹកប្រាក់ជំពាក់ពីក្រុមហ៊ុនពាក់ព័ន្ធ និងទ្រព្យសកម្មហិរញ្ញវត្ថុផ្សេងៗ ត្រូវបានបង្ហាញនៅតម្លៃយោងនៃទ្រព្យសកម្មហិរញ្ញវត្ថុតាមប្រភេទនីមួយៗ ហើយដែលត្រូវបានទទួលស្គាល់នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។

ដោយមិនគិតពីការវិភាគខាងលើការកើនឡើងហានិភ័យឥណទានជាសារវន្តត្រូវបានសន្មតប្រសិនបើកូនបំណុលមានការខកខានសងលើសពី ៣០ថ្ងៃ យោងតាមកិច្ចសន្យាក្នុងការទូទាត់។

នៅចុងការិយបរិច្ឆេទក្រុមហ៊ុនមិនបានទទួលស្គាល់ការបាត់បង់ពីឱនភាពតម្លៃសម្រាប់គណនីត្រូវទទួល ទឹកប្រាក់ជំពាក់ពីភាគីពាក់ព័ន្ធ និងទ្រព្យសកម្មហិរញ្ញវត្ថុផ្សេងៗ។

### (ខ) ហានិភ័យនៃការបង្វិលជាសាច់ប្រាក់

ហានិភ័យនៃការបង្វិលជាសាច់ប្រាក់ គឺជាហានិភ័យដែលក្រុមហ៊ុនជួបប្រទះការលំបាកក្នុងការបំពេញកាតព្វកិច្ចផ្នែកហិរញ្ញវត្ថុនៅពេលដល់កាលកំណត់។ ហានិភ័យនៃការបង្វិលជាសាច់ប្រាក់របស់ក្រុមហ៊ុនកើតឡើងជាចម្បងមកពីភាពមិនស៊ីគ្នានៃកាលកំណត់រវាងទ្រព្យសកម្មហិរញ្ញវត្ថុ និងបំណុល។ ការប្រឈមរបស់ក្រុមហ៊ុនចំពោះហានិភ័យនៃការបង្វិលជាសាច់ប្រាក់កើតឡើងជាចម្បងពី គណនីត្រូវទូទាត់ពាណិជ្ជ និងគណនីត្រូវទូទាត់ផ្សេងៗ គណនីត្រូវទូទាត់ទៅសម្ព័ន្ធញាតិ ឥណទាន និងប្រាក់កម្ចី និងបំណុលភតិសន្យា។

គោលបំណងរបស់ក្រុមហ៊ុន គឺដើម្បីរក្សាតុល្យភាពរវាងការបន្តផ្តល់ដើមទុន និងភាពបត់បែនក្នុងការប្រើប្រាស់ឧបករណ៍បំណុលដែលមាន។ ខណៈពេលដែលការគ្រប់គ្រង និងផ្តល់សុវត្ថិភាពដល់ចលនាសាច់ប្រាក់ក្រុមហ៊ុនរក្សាការបង្វិលជាសាច់ប្រាក់ និងដើមទុនគ្រប់គ្រាន់ដើម្បីបំពេញតំរូវការសាច់ប្រាក់ប្រចាំថ្ងៃ។ ក្រុមហ៊ុនធ្វើប្រតិបត្តិការជាបន្តបន្ទាប់ដើម្បីទទួលបានអត្ថប្រយោជន៍អតិបរិមាពីលំហូរដើមទុនរបស់ខ្លួន ដូចជាត្រូវបានគ្រប់គ្រងប្រកបដោយប្រសិទ្ធភាពដើម្បីបង្កើនប្រាក់ចំណូលពីការវិនិយោគ និងកាត់បន្ថយចំណាយលើប្រាក់កម្ចី។ នាយកដ្ឋានរតនាគាររបស់ ក្រុមហ៊ុនក៏ត្រូវធានាផងដែរថាមានភាពគ្រប់គ្រាន់នូវឧបករណ៍បំណុលដែលមិនទាន់ប្រើប្រាស់ មូលនិធិ និងទ្រព្យសកម្មដែលងាយបម្លែងជាសាច់ប្រាក់ដើម្បីបង្គ្រប់តម្រូវការថវិការយៈពេលខ្លី និងរយៈពេលវែង។

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

### ២៦. ឧបករណ៍ហិរញ្ញវត្ថុ (ត)

(ខ) ហានិភ័យនៃការបង្វិលជាសាច់ប្រាក់ (ត)

**ការវិភាគពីកាលកំណត់**

តារាងខាងក្រោមនេះរៀបរាប់អំពីការវិភាគកាលកំណត់នៃបំណុលហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ដោយផ្អែកលើកាលវសាននៅចុងការិយបរិច្ឆេទរាយការណ៍គឺផ្អែកលើកាតព្វកិច្ចទូទាត់សងដែលមិនមានការបញ្ចុះតម្លៃដូចចែងក្នុងកិច្ចសន្យាដែលត្រូវសងដូចខាងក្រោម៖

| | តម្លៃយោង ដុល្លារអាមេរិក | ពាន់រៀល | សរុប ដុល្លារអាមេរិក | ក្នុងរយៈពេល១ឆ្នាំ ឬតាមតម្រូវការ ដុល្លារអាមេរិក | ច្រើនជាង១ឆ្នាំ តែមិនលើសពី៥ឆ្នាំ ដុល្លារអាមេរិក | ច្រើនជាង៥ឆ្នាំ ដុល្លារអាមេរិក |
|---|---|---|---|---|---|---|
| **នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣** | | | | | | |
| គណនីត្រូវទូទាត់ពាណិជ្ជ និងគណនីត្រូវទូទាត់ផ្សេងៗ | ៨.៥០៤.៩១៧ | ៣៤.៧៤២.៥៨៦ | ៨.៥០៤.៩១៧ | ៨.៥០៤.៩១៧ | - | - |
| គណនីត្រូវទូទាត់ទៅសម្ព័ន្ធញាតិ | ២២.៨២៥.៨១១ | ៩៣.២៤៣.៤៣៨ | ២២.៨២៥.៨១១ | ២២.៨២៥.៨១១ | - | - |
| ឥណទាន និងប្រាក់កម្ចី | ៧៧.៣៣៣.៤០៧ | ៣១៥.៩០៦.៩១៨ | ៨៤.៤៨១.០២១ | ៤៩.៧១៧.២៧២ | ៣៤.៧៦៣.៧៤៩ | - |
| បំណុលភតិសន្យា | ២៧.៦៧៩.៣០៨ | ១១៣.០៦៩.៩៧៣ | ១០១.១២៧.១២៣ | ៣.២០៤.៥៣២ | ១១.៩២២.១៣១ | ៨៦.០០០.៤៦០ |
| | ១៣៦.៣៤៣.៤៤៣ | ៥៥៦.៩៦២.៩១៥ | ២១៦.៩៣៨.៨៧២ | ៨៤.២៥២.៥៣២ | ៤៦.៦៨៥.៨៨០ | ៨៦.០០០.៤៦០ |
| **នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២** | | | | | | |
| គណនីត្រូវទូទាត់ពាណិជ្ជ និងគណនីត្រូវទូទាត់ផ្សេងៗ | ៩.៦៦៨.០០៥ | ៣៩.៨០៣.១៧៦ | ៩.៦៦៨.០០៥ | ៩.៦៦៨.០០៥ | - | - |
| គណនីត្រូវទូទាត់ទៅសម្ព័ន្ធញាតិ | ១៥.៧៧០.៣៧៥ | ៦៤.៩២៦.៦៣៤ | ១៥.៧៧០.៣៧៥ | ១៥.៧៧០.៣៧៥ | - | - |
| ឥណទាន និងប្រាក់កម្ចី | ៥៣.៦៤៣.៨១៥ | ២២០.៨៥១.៥៨៥ | ៥៨.៩១៥.៩១៩ | ៤៨.២៨៩.៧៣៤ | ១០.៦២៦.១៨៥ | - |
| បំណុលភតិសន្យា | ៣.៥៥៧.២៣៣ | ១៤.៦៤៥.១២៨ | ៤.៦៤២.៣២២ | ១.៤៣៣.២៧៥ | ១.៩៥៦.៧៤០ | ១.២៥២.៣០៧ |
| | ៨២.៦៣៩.៤២៨ | ៣៤០.២២៦.៥២៣ | ៨៨.៩៩៦.៦២១ | ៧៥.១៦១.៣៨៩ | ១២.៥៨២.៩២៥ | ១.២៥២.៣០៧ |

# កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ
# សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

## ២៦. ឧបករណ៍ហិរញ្ញវត្ថុ (ត)

### (គ) ហានិភ័យអត្រាការប្រាក់

ហានិភ័យអត្រាការប្រាក់ គឺជាហានិភ័យដែលលំហូរសាច់ប្រាក់នាពេលអនាគតរបស់ក្រុមហ៊ុននឹងប្រែប្រួល ដោយសារតែមានការផ្លាស់ប្តូរជាសារវន្តនៃអត្រាការប្រាក់ទីផ្សារ។

ហានិភ័យអត្រាការប្រាក់របស់ក្រុមហ៊ុនកើតឡើងពីឥណទាន និងប្រាក់កម្ចី។ ឥណទាន និងប្រាក់កម្ចីជាហានិភ័យនៃការឡើងចុះនៃតម្លៃសមស្រប ឬលំហូរសាច់ប្រាក់ដែលជាលទ្ធផលបណ្តាលឱ្យមានហានិភ័យនៃការប្រាក់។

<u>ការវិភាគភាពប្រែប្រួលសម្រាប់ហានិភ័យអត្រាការប្រាក់</u>

តារាងខាងក្រោម បង្ហាញពីភាពប្រែប្រួលទៅនឹងការផ្លាស់ប្តូរអត្រាការប្រាក់ដ៏សមស្របដោយមានភាពខុសៗគ្នារវាងមូលធនសរុបរបស់ក្រុមហ៊ុន និងប្រាក់ចំណេញសម្រាប់ការិយបរិច្ឆេទ៖

| | បម្រែបម្រួលនៅក្នុងចំនុចមូលដ្ឋាន (១/១០.០០០) | ប៉ះពាល់ទៅលើចំណេញឬខាត ដុល្លារអាមេរិក | ប៉ះពាល់ទៅលើមូលធន ដុល្លារអាមេរិក | ពាន់រៀល |
|---|---|---|---|---|
| **នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣** | | | | |
| ឥណទាន និងប្រាក់កម្ចី | + ៥០ | (២៥.១៧១) | (២៥.១៧១) | (១០២.៨២៤) |
| | - ៥០ | ២៥.១៧១ | ២៥.១៧១ | ១០២.៨២៤ |
| ប័ណ្ណបំណុលសាជីវកម្ម | + ៥០ | (៤.៣៥៤) | (៤.៣៥៤) | (១៧.៧៨៦) |
| | - ៥០ | ៤.៣៥៤ | ៤.៣៥៤ | ១៧.៧៨៦ |
| **នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២** | | | | |
| ឥណទាន និងប្រាក់កម្ចី | + ៥០ | (៨.១០៥) | (៨.១០៥) | (៣៣.៣៦៨) |
| | - ៥០ | ៨.១០៥ | ៨.១០៥ | ៣៣.៣៦៨ |
| ប័ណ្ណបំណុលសាជីវកម្ម | + ៥០ | (៥.៧៨៤) | (៥.៧៨៤) | (២៣.៨១៣) |
| | - ៥០ | ៥.៧៨៤ | ៥.៧៨៤ | ២៣.៨១៣ |

### (ឃ) ហានិភ័យរូបិយប័ណ្ណបរទេស

ហានិភ័យរូបិយប័ណ្ណបរទេស គឺជាហានិភ័យទៅលើបម្រែបម្រួលនៅក្នុងតម្លៃសមស្រប ឬលំហូរសាច់ប្រាក់នាពេលអនាគតនៃឧបករណ៍ហិរញ្ញវត្ថុដែលជាលទ្ធផលនៃការប្តូររូបិយប័ណ្ណបរទេស។ ការប្រឈមមុខរបស់ក្រុមហ៊ុនទៅនឹងហានិភ័យរូបិយប័ណ្ណបរទេសទាក់ទងចម្បងទៅលើសកម្មភាពប្រតិបត្តិការ នៅពេលដែលសាច់ប្រាក់ និងសមតុល្យសាច់ប្រាក់នៅធនាគារ គណនីអតិថិជនពាណិជ្ជកម្ម និងគណនីត្រូវទទួលផ្សេងៗ គណនីត្រូវទូទាត់ពាណិជ្ជកម្ម និងគណនីត្រូវទូទាត់ផ្សេងៗ ការលក់ ការទិញ និងប្រាក់កម្ចីត្រូវបានកំណត់ជារូបិយប័ណ្ណបរទេស។

**កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ**
**សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣**

## ២៦. ឧបករណ៍ហិរញ្ញវត្ថុ (ត)

### (ឃ) ហានិភ័យរូបិយប័ណ្ណបរទេស (ត)

ទ្រព្យសកម្ម និងបំណុលហិរញ្ញវត្ថុ ដែលមិនមានការការពាររបស់ក្រុមហ៊ុនដែលមិនត្រូវបានតំណាងនៅក្នុងរូបិយប័ណ្ណមុខងាររបស់ខ្លួនមានដូចខាងក្រោម៖

| | ២០២៣<br>ដុល្លារអាមេរិក | ២០២២<br>ដុល្លារអាមេរិក |
|---|---|---|
| <u>សាច់ប្រាក់ និងសាច់ប្រាក់សមមូល</u> | | |
| ខ្មែររៀល | ២.៨១៧.០៤០ | ៦៤.២០៣ |
| <u>គណនីអតិថិជនពាណិជ្ជកម្ម និងគណនីត្រូវទទួលផ្សេងៗ</u> | | |
| ខ្មែររៀល | - | ១៩.៥៨៧ |
| ផោនអង់គ្លេស | - | ៩៤.៨៧៩ |
| <u>គណនីត្រូវទូទាត់ពាណិជ្ជកម្ម និងគណនីត្រូវទូទាត់ផ្សេងៗ</u> | | |
| អឺរ៉ូ | (៣៩.០៨៩) | (១៥៩) |
| ផោនអង់គ្លេស | - | (៤៦.៦២១) |
| យេនជប៉ុន | (១៤៤.៣៣៥) | (៣០.៧៨០) |
| បាតថៃ | - | (៩៤១) |
| <u>ឥណទាន និងប្រាក់កម្ចី</u> | | |
| ខ្មែររៀល | (៩.៥៧០.៤៩៧) | (១៣.២២៣.០៤៩) |

រូបិយប័ណ្ណបរទេសចម្បងរបស់ក្រុមហ៊ុនការប៉ះពាល់ភាគច្រើនទាក់ទងនឹងខ្មែររៀល។

<u>ការវិភាគសម្រាប់ហានិភ័យរូបិយប័ណ្ណបរទេស</u>

តារាងខាងក្រោមបង្ហាញការវិភាគ ក្នុងការវាយតម្លៃផលប៉ះពាល់ដែលអាចកើតមានឡើងក្នុង ការផ្លាស់ប្តូរនៃខ្មែររៀល ជាមួយនឹងអថេរផ្សេងទៀតដែលរក្សាថេរ៖

| | អត្រាផ្លាស់ប្តូរជា % | ការប៉ះពាល់លើចំណេញ ឬខាត<br>ដុល្លារអាមេរិក | ការប៉ះពាល់លើមូលធន<br>ដុល្លារអាមេរិក |
|---|---|---|---|
| **ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣** | | | |
| ខ្មែររៀល ឬដុល្លារអាមេរិក | + ៣% | (២០២.៦០៤) | (២០២.៦០៤) |
| | - ៣% | ២០២.៦០៤ | ២០២.៦០៤ |
| **ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២** | | | |
| ខ្មែររៀល ឬដុល្លារអាមេរិក | - ៣% | ៣៩៤.១៧៨ | ៣៩៤.១៧៨ |

## ២៦. ឧបករណ៍ហិរញ្ញវត្ថុ (ត)

### (ង) តម្លៃសមស្រប

**តម្លៃសមស្របនៅកម្រិត៣**

តម្លៃសមស្របនៃឧបករណ៍ហិរញ្ញវត្ថុត្រូវបានកត់ត្រាតាមតម្លៃសមស្រប

តម្លៃសមស្របនៃការវិនិយោគលើមូលធន ដែលមិនបោះផ្សាយលើទីផ្សារភាគហ៊ុនត្រូវបានប៉ាន់ស្មានដោយប្រើប្រាស់វិធីសាស្ត្រអប្បហារភាគលាភ។ ការវាយតម្លៃទាមទារឱ្យគណៈគ្រប់គ្រងធ្វើការសន្មតជាក់លាក់ពីវិធីសាស្ត្រធាតុចូលរួមមានការព្យាករណ៍លំហូរសាច់ប្រាក់ អត្រាអប្បហារ ហានិភ័យឥណទាន និងភាពប្រែប្រួល។ ប្រូបាបនៃការប៉ាន់ស្មានផ្សេងៗដែលនៅក្នុងលំដាប់អាចវាយតម្លៃដោយសមហេតុផល និងត្រូវបានប្រើប្រាស់ក្នុងការប៉ាន់ស្មានរបស់គណៈគ្រប់គ្រង ទៅលើតម្លៃសមស្របរបស់ការវិនិយោគទៅលើមូលប័ត្រដែលមាននៅលើទីផ្សារ។

| | តម្លៃយោង | | តម្លៃសមស្របនៃឧបករណ៍ហិរញ្ញវត្ថុត្រូវបានកត់ត្រាតាមតម្លៃសមស្រប |
|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក |
| **ការវិនិយោគផ្សេងៗ** | | | |
| នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ | ៥.៦០០.០០០ | ២២.៨៧៦.០០០ | ៥.៦០០.០០០ |
| នាថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២ | ៥.៦០០.០០០ | ២៣.០៥៥.២០០ | ៥.៦០០.០០០ |

តារាងខាងក្រោមបង្ហាញពីបច្ចេកទេសវាយតម្លៃដែលបានប្រើប្រាស់ក្នុងការកំណត់សមស្រប ក្នុងកម្រិតទី ៣ ក៏ដូចជាតម្លៃសំខាន់ដែលមិនអាចសង្កេតបាន។

| ការបរិយាយ | បច្ចេកទេសវាយតម្លៃ | ធាតុចូលនៃតម្លៃសំខាន់ដែលមិនអាចសង្កេតបាន | ទំនាក់ទំនងនៃធាតុចូលលើតម្លៃសំខាន់ដែលមិនអាចសង្កេតបានទៅនឹងតម្លៃសមស្រប |
|---|---|---|---|
| ការវិនិយោគទៅលើមូលបត្រភាគហ៊ុនដែលមិនមានក្នុងទីផ្សារ (FVTOCI) | វិធីសាស្ត្រអប្បហារភាគលាភ | វិធីសាស្ត្រវាយតម្លៃទ្រព្យសកម្មដោយផ្អែកលើវិធីសាស្ត្រអប្បហារ ១០ឆ្នាំ | ការកើនឡើងនៃភាគលាភនឹងបណ្តាលឱ្យមានការកើនឡើងនូវតម្លៃសមស្រប |

តម្លៃសមស្របនៃឧបករណ៍ហិរញ្ញវត្ថុមិនត្រូវបានកត់ត្រាតាមតម្លៃសមស្រប

តម្លៃសមស្របនៃបំណុលភតិសន្យា ត្រូវបានកំណត់ដោយប្រើវិធីសាស្ត្រលំហូរសាច់ប្រាក់បច្ចុប្បន្នដោយផ្អែកលើអត្រាការប្រាក់ដែលឆ្លុះបញ្ចាំងពីអត្រាខ្ចីរបស់អ្នកបោះផ្សាយលក់នៅចុងគ្រារាយការណ៍ ។

## ២៧. កិច្ចព្រមព្រៀងផ្សេងៗ

ក្រុមហ៊ុនបានបង្កើតកិច្ចព្រមព្រៀងសំរាប់ការចំណាយដើមទុនដូចខាងក្រោម៖

| | ២០២៣ | | ២០២២ | |
|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ | ៧៧៨.៣៩៩ | ៣.១៧៩.៧៦០ | ១.៥៥៩.៤៥៩ | ៦.៤២០.២៩៣ |
| ប័ណ្ណធានារបស់ធនាគារដែលមិនមានការធានាត្រូវបានចេញឱ្យអ្នកផ្គត់ផ្គង់ | ៦.០០០.០០០ | ២៤.៥១០.០០០ | ៦.៥៣០.៥១៧ | ២៦.៨៨៦.១៣៨ |
| ភតិសន្យា | ៣៥.២៨៤ | ១៤៥.០១៧ | ១៤.៧០៦ | ៦០.១០៣ |

## ២៨. ការគ្រប់គ្រងមូលធន

គោលបំណងចម្បងនៃការគ្រប់គ្រងមូលធនរបស់ក្រុមហ៊ុន គឺដើម្បីធានាថាវារក្សាបាននូវមូលដ្ឋានមូលធនដ៏រឹងមាំ និងការពារសមត្ថភាពរបស់ក្រុមហ៊ុនក្នុងការបន្តការប្រតិបត្តិការអាជីវកម្ម ដើម្បីផ្តល់ផលត្រឡប់មកវិញដល់ម្ចាស់ភាគហ៊ុន។

ដើមទុនរបស់ក្រុមហ៊ុនត្រូវបានតំណាងដោយភាគហ៊ុនសរុបរបស់ខ្លួន នៅក្នុងរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ។ ក្រុមហ៊ុនគ្រប់គ្រងដើមទុនដោយត្រួតពិនិត្យជាទៀងទាត់នូវតម្រូវការសាច់ប្រាក់ងាយស្រួលបច្ចុប្បន្ន និងរំពឹងទុករបស់ខ្លួន និងដើម្បីធានាបាននូវការអនុលោមតាមតម្រូវការដើមទុនដែលបានកំណត់ពីខាងក្រៅណាមួយ។

## ២៩. ពន្ធដាយថាហេតុ

ប្រព័ន្ធពន្ធដារនៅកម្ពុជាមានលក្ខណៈថ្មី ហើយត្រូវបានកំណត់ដោយពន្ធជាច្រើន និងមានការផ្លាស់ប្តូរជាច្បាប់ជាញឹកញាប់ ដែលមិនច្បាស់លាស់ ផ្ទុយ និងអាចបកស្រាយបាន។ ជាញឹកញាប់ការបកស្រាយខុសគ្នាមានក្នុងចំណោមអាជ្ញាធរពន្ធដារ និងយុត្តាធិការជាច្រើន។ ពន្ធត្រូវបានពិនិត្យ និងស៊ើបអង្កេតដោយអាជ្ញាធរមួយចំនួនដែលត្រូវបានអនុញ្ញាតដោយច្បាប់ក្នុងការដាក់ពិន័យ ពិន័យ និងការគិតការប្រាក់។ អង្គហេតុទាំងនេះ អាចបង្កើតហានិភ័យពន្ធនៅព្រះរាជាណាចក្រកម្ពុជាដែលគួរឱ្យកត់សម្គាល់ជាងប្រទេសដទៃទៀត។ គណៈគ្រប់គ្រងជឿជាក់ថាក្រុមហ៊ុនបានផ្តល់គ្រប់គ្រាន់សម្រាប់បំណុលពន្ធដោយផ្អែកលើការបកស្រាយច្បាប់ពន្ធ។ ទោះយ៉ាងណាក៏ដោយ អាជ្ញាធរពាក់ព័ន្ធអាចមានការបកស្រាយខុសគ្នាហើយមានផលប៉ះពាល់ធ្ងន់ធ្ងរ។

## ៣០. ព្រឹត្តិការណ៍សំខាន់ៗបន្ទាប់ពីចុងការិយបរិច្ឆេទ

នាថ្ងៃទី១១ ខែមករា ឆ្នាំ២០២៤ ភាគលាភចន្លោះពេលបន្ថែមប្រចាំខែចំនួន ៥.០០០.០០០ដុល្លារអាមេរិក (ស្មើនឹង ២០.៤៤៥.០០០.០០០រៀល) ត្រូវបានប្រកាសបែងចែកពីចំណូលសម្រាប់ការិយបរិច្ឆេទហិរញ្ញវត្ថុបញ្ចប់ឆ្នាំ២០២៣។ ភាគលាភនេះត្រូវបានទូទាត់នៅថ្ងៃទី១៧ ខែមករា ឆ្នាំ២០២៤។

របាយការណ៍ហិរញ្ញវត្ថុដែលបានធ្វើសវនកម្មរួចសម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ មិនបានបង្ហាញពីភាគលាភនេះជាបំណុលទេ។ ភាគលាភនេះនឹងត្រូវរាប់បញ្ចូលក្នុងមូលធននៃចំណេញរក្សាទុកនៅក្នុងត្រីមាស និងរយៈពេល៣ខែ បញ្ចប់ថ្ងៃទី៣១ ខែមីនា ឆ្នាំ២០២៤។

## ៣១. តួលេខប្រៀបធៀប

ចំនួនជាក់លាក់នៃរបាយការណ៍ហិរញ្ញវត្ថុប្រៀបធៀប និងការលាតត្រដាងកំណត់ចំណាំបានចាត់ថ្នាក់ឡើងវិញដើម្បីអនុលោមទៅតាមការបញ្ជាក់ឆ្នាំបច្ចុប្បន្ននៃគណនី។ អ្នកគ្រប់គ្រងជឿជាក់ថាការចាត់ថ្នាក់ឡើងវិញទាំងនេះនឹងឆ្លុះបញ្ចាំងកាន់តែច្បាស់អំពីលក្ខណៈនៃប្រតិបត្តិការ។

ការសង្ខេបពីបម្រែបម្រួលដែលកើតឡើងពីចាត់ថ្នាក់ឡើងវិញ ដែលបានបង្ហាញដូចខាងក្រោម៖

| | ដូចបានរាយការណ៍ពីមុន<br>ដុល្លារអាមេរិក | កែតម្រូវឡើងវិញ<br>ដុល្លារអាមេរិក | ដូចបានចាត់ថ្នាក់ឡើងវិញ<br>ដុល្លារអាមេរិក |
|---|---|---|---|
| <u>របាយការណ៍លំហូរសាច់ប្រាក់</u> | | | |
| **និយ័តកម្មលើ៖** | | | |
| ឱនភាពតម្លៃលើគណនីពាណិជ្ជត្រូវទទួល | | | |
| - សំវិធានធន | ៩១.៧៧៦ | (៩១.៧៧៦) | - |
| - ការកត់ត្រាត្រឡប់មកវិញនៃសំវិធានធន | (៨៧៤.៣៦៩) | ៨៧៤.៣៦៩ | - |
| ការកត់ត្រាត្រឡប់មកវិញនៃការខាតបង់ ឱនភាពតម្លៃលើគណនីពាណិជ្ជត្រូវទទួល | - | (៧៨២.៥៩៣) | (៧៨២.៥៩៣) |
| **បម្រែបម្រួលទុនបង្វិល៖** | | | |
| ភាគីពាក់ព័ន្ធ | ១២.៤១២.៥៧៣ | (១២.៤១២.៥៧៣) | - |
| ទឹកប្រាក់ជំពាក់ពីភាគីពាក់ព័ន្ធ | - | (១.៩៧១.៧៤២) | (១.៩៧១.៧៤២) |
| ទឹកប្រាក់ជំពាក់ទៅភាគីពាក់ព័ន្ធ | - | ១៤.៣៨៤.៣១៥ | ១៤.៣៨៤.៣១៥ |
| **សកម្មភាពវិនិយោគ** | | | |
| ការផ្លាស់ប្តូរលើការធានាសញ្ញាប័ណ្ណ | (៣.៥១១.១២២) | ៣.៥១១.១២២ | - |
| **សកម្មភាពហិរញ្ញប្បទាន** | | | |
| ការផ្លាស់ប្តូរលើការធានាសញ្ញាប័ណ្ណ | - | (៣.៥១១.១២២) | (៣.៥១១.១២២) |

## កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ
## សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

### ៣២. ព័ត៌មានតាមផ្នែក

ក្រុមហ៊ុនចម្រុះដែលទទួលបានប្រាក់ចំណូល និងប្រាក់ចំណេញពីប្រភពផ្សេងៗគ្នា។ ប្រធានប្រតិបត្តិការរបស់ក្រុមហ៊ុន ដែលជាអ្នកធ្វើការសំរេចចិត្តពោលគឺប្រធាននាយកប្រតិបត្តិធ្វើការគិតគូរអាជីវកម្មដែលទទួលបានពីផលិតផល និងសេវាកម្មផ្សេងៗហើយបានកំណត់ផ្នែកដែលអាចរាការណ៍បានចំនួនមួយ។

ផ្នែកហុងដ - ធ្វើទីផ្សារ និងលក់រថយន្តហុងដ សេវាកម្មជួសជុល និងគ្រឿងបន្លាស់។

ផ្នែកប្រតិបត្តិការ - ធ្វើទីផ្សារ និងលក់គ្រឿងម៉ាស៊ីន ឧបករណ៍ និងសេវាកម្មថែទាំលើឧបករណ៍ រថយន្ត និងគ្រឿងបន្លាស់ ក្រៅពីផ្នែកហុងដ។

ពុំមានផ្នែកណាមួយនៃប្រតិបត្តិការទាំងនោះ ត្រូវបានជាប់លក្ខខណ្ឌជាផ្នែកដែលត្រូវរាយការណ៍នោះទេ។

<u>ចំណេញតាមផ្នែក</u>

ការអនុវត្តតាមផ្នែកត្រូវបានដាក់ចេញដើម្បីវាស់ស្ទង់ការអនុវត្តការងារ ដែលនាយកប្រតិបត្តិជឿជាក់ថាព័ត៌មានបែបនេះគឺមានភាពពាក់ព័ន្ធសំខាន់បំផុតក្នុងការវាយតម្លៃលទ្ធផលនៃផ្នែកជាក់លាក់ ដែលទាក់ទងទៅនឹងអង្គភាពផ្សេងទៀតដែលមានប្រតិបត្តិការនៅក្នុងឧស្សាហកម្មប្រភេទនេះ។ សមិទ្ធផលត្រូវបានវាយតម្លៃដោយផ្អែកលើប្រាក់ចំណេញប្រតិបត្តិការ ឬការខាតបង់ ដែលត្រូវបានធ្វើការវាស់វែងខុសពីប្រាក់ចំណេញប្រតិបត្តិការ ឬខាតបង់នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុ។

<u>ទ្រព្យសកម្មតាមផ្នែក</u>

ទ្រព្យសកម្មតាមផ្នែកសរុបត្រូវបានវាស់វែងដោយផ្អែកលើទ្រព្យសកម្មទាំងអស់នៃផ្នែក ដែលរួមបញ្ចូលនៅក្នុងរបាយការណ៍ផ្ទៃក្នុងដែលត្រួតពិនិត្យដោយនាយកប្រតិបត្តិ។

<u>បំណុលតាមផ្នែក</u>

បំណុលតាមផ្នែកសរុបត្រូវបានវាស់វែងដោយផ្អែកលើបំណុលទាំងអស់នៃផ្នែក ដែលរួមបញ្ចូលនៅក្នុងរបាយការណ៍ផ្ទៃក្នុងដែលត្រួតពិនិត្យដោយនាយកប្រតិបត្តិ។

# កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ
# សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

## ៣២. ព័ត៌មានតាមផ្នែក (ត)

តារាងខាងក្រោមបង្ហាញពីព័ត៌មានតាមផ្នែក សម្រាប់ផ្នែកដែលអាចរាយការណ៍បានសម្រាប់ការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ និងឆ្នាំ២០២២៖

| | ក្រុមហ៊ុន ហ្វង | | ប្រតិបត្តិការផ្សេងៗ | | សាជីវកម្ម និងការលុបបំបាត់ | | សរុប | |
|---|---|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| **គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣** | | | | | | | | |
| សរុបចំណូលតាមផ្នែក | ៣៨៦.១១២.៦៧៨ | ១.៥៨៦.៩២៣.១០៧ | ៥៨.៩៥១.៣៨១ | ២៤២.២៩០.១៧៦ | - | - | ៤៤៥.០៦៤.០៥៩ | ១.៨២៩.២១៣.២៨៣ |
| ចំណូលតាមផ្នែកអន្តរ | - | - | - | - | (៧.០១៩.៧៥៤) | (២៨.៨៥១.១៨៩) | (៧.០១៩.៧៥៤) | (២៨.៨៥១.១៨៩) |
| | ៣៨៦.១១២.៦៧៨ | ១.៥៨៦.៩២៣.១០៧ | ៥៨.៩៥១.៣៨១ | ២៤២.២៩០.១៧៦ | (៧.០១៩.៧៥៤) | (២៨.៨៥១.១៨៩) | ៤៣៨.០៤៤.៣០៥ | ១.៨០០.៣៦២.០៩៤ |
| ចំណូលពី៖ | | | | | | | | |
| -អតិថិជនខាងក្រៅ | ៣៤៩.១១៦.១៥១ | ១.៤៣៤.៨៦៧.៣៨១ | ៥០.៣០៥.០៨៨ | ២០៦.៧៥៣.៩១២ | - | - | ៣៩៩.៤២១.២៣៩ | ១.៦៤១.៦២១.២៩៣ |
| -សម្ព័ន្ធញាតិ | ៣៦.៩៩៦.៥២៧ | ១៥២.០៥៥.៧២៦ | ៨.៦៤៦.២៩៣ | ៣៥.៥៣៦.២៦៤ | (៧.០១៩.៧៥៤) | (២៨.៨៥១.១៨៩) | ៣៨.៦២៣.០៦៦ | ១៥៨.៧៤០.៨០១ |
| | ៣៨៦.១១២.៦៧៨ | ១.៥៨៦.៩២៣.១០៧ | ៥៨.៩៥១.៣៨១ | ២៤២.២៩០.១៧៦ | (៧.០១៩.៧៥៤) | (២៨.៨៥១.១៨៩) | ៤៣៨.០៤៤.៣០៥ | ១.៨០០.៣៦២.០៩៤ |
| **ចំណេញតាមផ្នែក*** | ៤៣.៤៤៣.៤៣៥ | ១៧៨.៥៥២.៥១៨ | ១.៥៨៨.៧១៥ | ៦.៥២៩.៦១៩ | - | - | ៤៥.០៣២.១៥០ | ១៨៥.០៨២.១៣៧ |

**កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ**
**សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣**

## ៣២. ព័ត៌មានតាមផ្នែក (ត)

តារាងខាងក្រោមបង្ហាញពីព័ត៌មានតាមផ្នែក សម្រាប់ផ្នែកដែលអាចរាយការណ៍បានសម្រាប់ការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ និងឆ្នាំ២០២២ ៖ (ត)

| | ក្រុមហ៊ុន ហ្វដ | | ប្រតិបត្តិការផ្សេងៗ | | សាជីវកម្ម និងការលុបបំបាត់ | | សរុប | |
|---|---|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| **គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២** | | | | | | | | |
| សរុបចំណូលតាមផ្នែក | ៤៩៧.៩២២.៣៩៥ | ២.០៣៥.០០៨.៨២៨ | ៥០.៤៧៨.២១០ | ២០៦.៣០៤.៤៤៤ | - | - | ៥៤៨.៤០០.៦០៥ | ២.២៤១.៣១៣.២៧២ |
| ចំណូលតាមផ្នែកអន្តរ | - | - | - | - | (៩.៣១២.៤១០) | (៣៨.០៥៩.៨១៩) | (៩.៣១២.៤១០) | (៣៨.០៥៩.៨១៩) |
| | ៤៩៧.៩២២.៣៩៥ | ២.០៣៥.០០៨.៨២៨ | ៥០.៤៧៨.២១០ | ២០៦.៣០៤.៤៤៤ | (៩.៣១២.៤១០) | (៣៨.០៥៩.៨១៩) | ៥៣៩.០៨៨.១៩៥ | ២.២០៣.២៥៣.៤៥៣ |
| ចំណូលពី៖ | | | | | | | | |
| -អតិថិជនខាងក្រៅ | ៤៤០.៤០៦.៤៩៩ | ១.៧៩៩.៩៤១.៣៦១ | ៣៤.៩៩៩.៤៧៤ | ១៤៣.០៤២.៨៥០ | - | - | ៤៧៥.៤០៥.៩៧៣ | ១.៩៤២.៩៨៤.២១១ |
| -សម្ព័ន្ធញាតិ | ៥៧.៥១៥.៨៩៦ | ២៣៥.០៦៧.៤៦៧ | ១៥.៤៧៨.៧៣៦ | ៦៣.២៦១.៥៩៤ | (៩.៣១២.៤១០) | (៣៨.០៥៩.៨១៩) | ៦៣.៦៨២.២២២ | ២៦០.២៦៩.២៤២ |
| | ៤៩៧.៩២២.៣៩៥ | ២.០៣៥.០០៨.៨២៨ | ៥០.៤៧៨.២១០ | ២០៦.៣០៤.៤៤៤ | (៩.៣១២.៤១០) | (៣៨.០៥៩.៨១៩) | ៥៣៩.០៨៨.១៩៥ | ២.២០៣.២៥៣.៤៥៣ |
| **ចំណេញតាមផ្នែក*** | ៧៧.៨៨៨.៤២៣ | ៣១៨.៣២៩.៩៨៥ | ២.៨៤៨.៣៥៥ | ១១.៦៤១.២២៧ | - | - | ៨០.៧៣៦.៧៧៨ | ៣២៩.៩៧១.២១២ |

# កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ
# សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

## ៣២. ព័ត៌មានតាមផ្នែក (ត)

តារាងខាងក្រោមបង្ហាញពីព័ត៌មានតាមផ្នែក សម្រាប់ផ្នែកដែលអាចរាយការណ៍បានសម្រាប់ការិយបរិច្ឆេទថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ និងឆ្នាំ២០២២៖ (ត)

| | ក្រុមហ៊ុន ហ្វដ | | ប្រតិបត្តិការផ្សេងៗ | | សាជីវកម្ម និងការលុបបំបាត់ | | សរុប | |
|---|---|---|---|---|---|---|---|---|
| | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល | ដុល្លារអាមេរិក | ពាន់រៀល |
| **ថ្ងៃទី៣១ ខែធ្នូ ២០២៣** | | | | | | | | |
| សរុបទ្រព្យសកម្មតាមផ្នែក | ១៩១.៧៣៤.០៩២ | ៧៨៣.២៣៣.៧៦៦ | ៧៥.៩៥៥.៤៣៣ | ៣១០.២៧៧.៩៤៤ | - | - | ២៦៧.៦៨៩.៥២៥ | ១.០៩៣.៥១១.៧១០ |
| សរុបបំណុលតាមផ្នែក | ១២១.២១១.១២១ | ៤៩៥.១៤៧.៤២៩ | ២២.៣៨៩.៧៩៦ | ៩១.៤៦២.៣១៧ | - | - | ១៤៣.៦០០.៩១៧ | ៥៨៦.៦០៩.៧៤៦ |
| **ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២២** | | | | | | | | |
| សរុបទ្រព្យសកម្មតាមផ្នែក | ១៦៨.២៦៧.៣២៣ | ៦៩២.៧៥៦.៥៧៩ | ៤៧.៧៣៨.៣២០ | ១៩៦.៥៣៨.៦៦៣ | - | - | ២១៦.០០៥.៦៤៣ | ៨៨៩.២៩៥.២៣២ |
| សរុបបំណុលតាមផ្នែក | ៩៥.៣៩៥.៧៣៨ | ៣៩២.៧៤៤.២៥៣ | ១៤.២៤៥.៣៦៨ | ៥៨.៦៤៨.១៨០ | - | - | ១០៩.៦៤១.១០៦ | ៤៥១.៣៩២.៤៣៣ |

# កំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ
# សម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣

## ៣២. ព័ត៌មានតាមផ្នែក (ត)

(*) នាយកប្រតិបត្តិ សម្រេចចិត្តប្រើប្រាស់ចំណេញតាមផ្នែកជារង្វាស់សម្រាប់ធ្វើការវាយតម្លៃដំនើរការអនុវត្តតាមផ្នែក។ នេះមិនរាប់បញ្ចូលផលប៉ះពាល់នៃធាតុសំខាន់ៗនៃប្រាក់ចំណូល និងចំណាយ ដែលអាចជះឥទ្ធិពលដល់គុណភាពរកប្រាក់ចំណូល ចំណាយផ្នែកច្បាប់ និងការថយចុះតម្លៃនៅពេលដែលលទ្ធផលនៃការថយចុះនៃតម្លៃមានភាពឆ្ងាយ ព្រឹត្តិការណ៍មិនកើតឡើងជាដដែលៗឡើយ។ វាក៏មិនរាប់បញ្ចូលផលប៉ះពាល់នៃចំណេញ ឬខាតបង់ទាំងឡាយណាដែលមិនបានទទួលស្គាល់នៅក្នុងឧបករណ៍ហិរញ្ញវត្ថុនោះទេ។

ការផ្ទៀងផ្ទាត់ចំណេញតាមផ្នែក ទៅនឹងប្រាក់ចំណេញប្រតិបត្តិការមុនបង់ពន្ធត្រូវបានបង្ហាញដូចខាងក្រោម៖

| | ២០២៣ | | ២០២២ | |
|---|---|---|---|---|
| | **ដុល្លារអាមេរិក** | **ពាន់រៀល** | **ដុល្លារអាមេរិក** | **ពាន់រៀល** |
| **ចំណេញតាមផ្នែក** | ៤៥.០៣២.១៥០ | ១៨៥.០៨២.១៣៧ | ៨០.៧៣៦.៧៧៨ | ៣២៩.៩៧១.២១២ |
| រំលស់នៃ៖ | | | | |
| - ទ្រព្យសម្បត្តិ រោងចក្រ និងបរិក្ខារ | (៣.៦៦៦.៥៧៨) | (១៥.០៦៩.៦៣៦) | (៣.២១៥.១០៩) | (១៣.១៤០.១៥០) |
| - សិទ្ធិក្នុងការប្រើប្រាស់ទ្រព្យសកម្ម | (១.៦១៦.៤៨០) | (៦.៦៤៣.៧៣៣) | (១.២២៥.៣៨៤) | (៥.០០៨.១៤៤) |
| ចំណូលភាគលាភ | - | - | ៥០០.១២០ | ២.០៤៣.៩៩០ |
| ចំណាយហិរញ្ញប្បទាន | (៧.១៥៦.៣១៤) | (២៩.៤១២.៤៥១) | (៣.១៣២.៣៥៧) | (១២.៨០១.៩៤៣) |
| ចំណូលហិរញ្ញប្បទាន | ៦៣៨.០៩៧ | ២.៦២២.៥៧៩ | ១.១៧៥.៨៤១ | ៤.៨០៥.៦៦២ |
| ការកត់ត្រាត្រឡប់មកវិញនៃការខាតបង់ ឱនភាពតម្លៃលើគណនីពាណិជ្ជត្រូវទទួល | ៦.២៦១ | ២៥.៧៣៣ | ៧៨២.៥៩៣ | ៣.១៩៨.៤៥៨ |
| ការខាតបង់ឱនភាពតម្លៃពីការវិនិយោគ នៅក្នុងក្រុមហ៊ុនញាតិសម្ព័ន្ធ | - | - | (២៥០.០០០) | (១.០២១.៧៥០) |
| (ការកត់ត្រាត្រឡប់មកវិញ)/សំវិធានធន នៃការខាតបង់ឱនភាពតម្លៃលើការធានា | ៩៩៨.០០០ | ៤.១០១.៧៨០ | (៩៩៨.០០០) | (៤.០៧៨.៨២៦) |
| សន្និធិដែលមានចលនាយឺតយ៉ាវ | | | | |
| - សំវិធានធន | (២.៤៩៩.៣៤៧) | (១០.២៥១.៧៦៦) | (៣.១៤២.៦៣០) | (១២.៨៤៣.៩២៩) |
| - ការកត់ត្រាត្រឡប់មកវិញនៃសំវិធានធន | ១.៩៣៧.១១៩ | ៧.៩៦១.៥៥៩ | ៨៦៣.២៣២ | ៣.៥២៨.០២៩ |
| - ការលុបចោល | ២៤៤.៣០៦ | ១.០០៤.០៩៨ | ៣៤៤.០៩២ | ១.៤០៦.៣០៤ |
| **ចំណេញមុនបង់ពន្ធ** | ៣៣.៩២២.២១៤ | ១៣៩.៤២០.៣០០ | ៧២.៤៣៩.១៧៦ | ២៩៦.០៥៨.៩១៣ |

## ៣៣. សិទ្ធិអនុម័តនៃរបាយការណ៍ហិរញ្ញវត្ថុ

របាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនសម្រាប់ការិយបរិច្ឆេទបញ្ចប់ថ្ងៃទី ថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ ត្រូវបានអនុញ្ញាតឱ្យចេញផ្សាយដោយស្របតាមសេចក្តីសម្រេចរបស់ក្រុមប្រឹក្សាភិបាល ចុះថ្ងៃទី២៧ ខែមីនា ឆ្នាំ២០២៤។

bakertilly

Baker Tilly (Cambodia) Co., Ltd.
Certified Public Accountants
No. 87, Street 294,
Sangkat Boeung Keng Kang 1,
120102, Khan Boeung Keng Kang,
Phnom Penh, Cambodia.

T: +855 23 987 100/
+855 23 987 388

info@bakertilly.com.kh
**www.bakertilly.com.kh**

លេខយោង៖GA/0046/0424/R001-0064/KMT

**របាយការណ៍សវនករឯករាជ្យជូនចំពោះភាគទុនិក**
**ក្រុមហ៊ុន អ អិម អេ (ខេមបូឌា) ម.ក**

## របាយការណ៍ស្តីពីសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ

### មតិសវនកម្ម

យើងខ្ញុំបានធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន អ អឹម អេ (ខេមបូឌា) ម ក.ហៅកាត់ថា "ក្រុមហ៊ុន" ដែលរួមមានរបាយការណ៍ស្ថានភាពហិរញ្ញវត្ថុ គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ និងរបាយការណ៍លទ្ធផលលម្អិត របាយការណ៍បម្រែបម្រួលមូលធន និងរបាយការណ៍លំហូរសាច់ប្រាក់របស់ក្រុមហ៊ុនសម្រាប់ការិយបរិច្ឆេទដែលបានបញ្ចប់ និងកំណត់សម្គាល់លើរបាយការណ៍ហិរញ្ញវត្ថុ រួមទាំងសេចក្តីសង្ខេបគោលការណ៍គណនេយ្យជាសារវន្ត ព្រមទាំងព័ត៌មានពន្យល់ផ្សេងៗ ដូចមានចែងពីទំព័រទី ៥ ដល់ ៦៥។

តាមមតិរបស់យើងខ្ញុំ របាយការណ៍ហិរញ្ញវត្ថុបានបង្ហាញនូវទិដ្ឋភាពពិត និងត្រឹមត្រូវនៃស្ថានភាពហិរញ្ញវត្ថុរបស់ក្រុមហ៊ុន គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ ព្រមទាំងលទ្ធផលហិរញ្ញវត្ថុ និងលំហូរសាច់ប្រាក់សម្រាប់ការិយបរិច្ឆេទបញ្ចប់ដោយអនុលោមតាមស្តង់ដាររបាយការណ៍ទាក់ទងនឹងហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា ("ស.រ.ទ.ហ.អ.ក")។

### មូលដ្ឋានមតិសវនកម្ម

យើងខ្ញុំបានធ្វើសវនកម្មដោយអនុលោមទៅតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា ("ស.អ.ក")។ ទំនួលខុសត្រូវរបស់យើងខ្ញុំ ដែលស្របតាមស្តង់ដារទាំងនោះ ត្រូវបានរៀបរាប់បន្ថែមនៅក្នុងកថាខណ្ឌស្តីពីទំនួលខុសត្រូវរបស់សវនករសម្រាប់ការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុដែលមាននៅក្នុងរបាយការណ៍របស់យើងខ្ញុំ។ យើងខ្ញុំមានភាពឯករាជ្យពីក្រុមហ៊ុនដោយស្របតាមក្រមសីលធម៌អន្តរជាតិសម្រាប់ក្រមសីលធម៌វិជ្ជាជីវៈគណនេយ្យករ ("IESBA Code") ដែលចេញផ្សាយដោយក្រុមប្រឹក្សាក្រមសីលធម៌អន្តរជាតិសម្រាប់គណនេយ្យករ និងតាមតម្រូវការក្រមសីលធម៌ដែលជាប់ទាក់ទងនឹងការធ្វើសវនកម្មរបស់យើងខ្ញុំលើរបាយការណ៍ហិរញ្ញវត្ថុនៅកម្ពុជា យើងខ្ញុំបានបំពេញទទួលខុសត្រូវលើក្រមសីលធម៌ផ្សេងទៀត ស្របតាមតម្រូវការនេះ។ យើងខ្ញុំជឿជាក់ថាភស្តុតាងសវនកម្មដែលយើងបានទទួល គឺគ្រប់គ្រាន់ និងសមរម្យដើម្បីផ្តល់ជាមូលដ្ឋានក្នុងការបញ្ចេញមតិសវនកម្មរបស់យើងខ្ញុំ។





Baker Tilly (Cambodia) Co., Ltd. trading as Baker Tilly is a member of the global network of Baker Tilly International Ltd., the members of which are separate and independent legal entities.

bakertilly

## បញ្ហាសវនកម្មសំខាន់ៗ

យោងតាមការវិនិច្ឆ័យដោយវិជ្ជាជីវៈរបស់យើងខ្ញុំ បញ្ហាសវនកម្មសំខាន់ៗគឺជាបញ្ហាទាំងឡាយណាដែលមានសារៈសំខាន់បំផុត នៅក្នុងការធ្វើសវនកម្មរបស់យើងខ្ញុំលើរបាយការណ៍ហិរញ្ញវត្ថុ របស់ក្រុមហ៊ុនសម្រាប់ឆ្នាំហិរញ្ញវត្ថុនេះ។ បញ្ហាទាំងនេះត្រូវបានបង្ហាញនៅក្នុងបរិបទ នៃការធ្វើសវនកម្មរបស់យើងខ្ញុំលើរបាយការណ៍ហិរញ្ញរបស់ក្រុមហ៊ុនទាំងមូល ហើយនៅក្នុងការបង្កើតមតិយោបល់របស់យើងខ្ញុំនាពេលបន្ទាប់ យើងខ្ញុំមិនផ្តល់នូវមតិយោបល់ដាច់ដោយឡែកចំពោះបញ្ហាទាំងនេះឡើយ។

**<u>ការវាយតម្លៃសន្និធិ</u>**

***<u>យោងតាមកំណត់សម្គាល់ ២(ច) កំណត់សម្គាល់ ៤(ត) និងកំណត់សម្គាល់ ៩ នៃរបាយការណ៍ហិរញ្ញវត្ថុ</u>***

គិតត្រឹមថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០២៣ តម្លៃយោងនៃសន្និធិនៃក្រុមហ៊ុនមានចំនួន ១៥៨.០០១.៣៤៤ដុល្លារអាមេរិក។

ក្រុមហ៊ុនបានកាន់កាប់កម្រិតសន្និធិជាសារវន្ត ដែលរួមមានយានជំនិះថ្មី និងគ្រឿងបន្លាស់ ("សន្និធិ") ។ លទ្ធភាពរបស់ក្រុមហ៊ុនក្នុងការលក់សន្និធិនាពេលអនាគតអាចរងផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរដោយកត្តាជាច្រើន រួមទាំងការផ្លាស់ប្តូរចំណង់ចំណូលចិត្តរបស់អ្នកប្រើប្រាស់ សកម្មភាពរបស់គូប្រកួតប្រជែង រួមមានទាំងតម្លៃ និងការណែនាំរថយន្តម៉ូតថ្មី។ ជាលទ្ធផលកត្តាទាំងនេះអាច នឹងនាំឱ្យមានហានិភ័យទៅលើម៉ូដែលមួយចំនួនដែលអាចនឹងត្រូវបានលក់ក្រោមតម្លៃយោង ហើយប្រហែលជាត្រូវលុបចេញពីបញ្ជីទៅតម្លៃពិតប្រាកដ។ នេះជាផ្នែកមួយដ៏សំខាន់សម្រាប់ការធ្វើសវនកម្មរបស់យើង ដោយសារការវាយតម្លៃសន្និធិគឺតម្រូវឱ្យគណៈគ្រប់គ្រងធ្វើការប៉ាន់ស្មាន និងការវិនិច្ឆ័យក្នុងការកំណត់ភាពសមស្របនៃការលុបចោលសន្និធិពីបញ្ជីទៅតម្លៃពិតប្រាកដ។

ហេតុដូចនេះ យើងបានកំណត់ថានេះជាបញ្ហាសវនកម្មសំខាន់។

<u>ការឆ្លើយតបរបស់យើង៖</u>

- យើងស្វែងយល់ពីការវាយតម្លៃដែលធ្វើឡើងដោយគណៈគ្រប់គ្រង ដើម្បីសម្រេចលើតម្លៃពិតប្រាកដនៃសន្និធិ
- យើងបានធ្វើតេស្តលើថ្លៃដើមនៃសន្និធិតាមម៉ូតគម្រូ
- យើងប្រៀបធៀបកម្រិតសន្និធិទៅនឹងនិន្នាការលក់ថ្មីៗរបស់ក្រុមហ៊ុន និង
- យើងប្រៀបធៀបថ្លៃដើមនៃសន្និធិទៅនឹងតម្លៃលក់ដែលរំពឹងទុក ដកជាមួយថ្លៃដើមនឹងត្រូវលក់តាមគម្រូ។ តម្លៃលក់ដែលរំពឹងទុក ដកជាមួយថ្លៃដើមនឹងត្រូវលក់គឺបានមកពីតម្លៃលក់ក្រោយចុងឆ្នាំដែលបានបោះពុម្ពផ្សាយដោយគម្រូសុទ្ធនៃការប៉ាន់ស្មានការបញ្ចុះតម្លៃ និងការប៉ាន់ស្មានរង្វាន់លើកទឹកចិត្តពីការលក់ និងចំណាយពាក់ព័ន្ធផ្សេងទៀតទៅលើការលក់។

ដោយផ្អែកទៅលើនីតិវិធីដែលបានអនុវត្តខាងលើយើងមិនបានកំណត់ឃើញថាមានកុំហុសឆ្គងជាសារវន្តណាមួយឡើយ។

## ព័ត៌មានក្រៅពីរបាយការណ៍ហិរញ្ញវត្ថុ និងរបាយការណ៍របស់សវនករ

ក្រុមប្រឹក្សាភិបាលរបស់ក្រុមហ៊ុនមានភារៈទទួលខុសត្រូវលើព័ត៌មានផ្សេងៗ។ ព័ត៌មានផ្សេងៗ រួមមានរបាយការណ៍របស់ក្រុមប្រឹក្សាភិបាល និងរបាយការណ៍ប្រចាំឆ្នាំ ប៉ុន្តែមិនរួមបញ្ចូលរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន និងរបាយការណ៍របស់សវនកររបស់យើងនៅទីនោះទេ។

មតិសវនកម្មរបស់យើងខ្ញុំលើរបាយការណ៍ហិរញ្ញវត្ថុ មិនគ្របដណ្តប់លើរបាយការណ៍ក្រុមប្រឹក្សាភិបាល ហើយយើងខ្ញុំក៏មិនបញ្ចេញអំណះអំណាងណាមួយទេ។

ពាក់ព័ន្ធនឹងការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ការទទួលខុសត្រូវរបស់យើងខ្ញុំ គឺត្រូវអានព័ត៌មានផ្សេងទៀត ហើយពិចារណាថាតើព័ត៌មានផ្សេងទៀតនោះ មានភាពមិនស្របគ្នាជាសារវន្តជាមួយរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ឬការយល់ដឹងរបស់យើងខ្ញុំនៅក្នុងការធ្វើសវនកម្ម ឬមានបង្ហាញនូវកំហុសឆ្គងជាសារវន្ត។

ប្រសិនបើផ្អែកលើការងារដែលយើងខ្ញុំបានអនុវត្ត យើងខ្ញុំសន្និដ្ឋានថាមានកំហុសឆ្គងជាសារវន្តនៃរបាយការណ៍របស់ក្រុមប្រឹក្សាភិបាល យើងខ្ញុំត្រូវរាយការណ៍ពីការពិតនោះ។ យើងខ្ញុំមិនមានអ្វីត្រូវរាយការណ៍ពីរឿងនេះទេ។

## ការទទួលខុសត្រូវរបស់ក្រុមប្រឹក្សាភិបាលលើរបាយការណ៍ហិរញ្ញវត្ថុ

ក្រុមប្រឹក្សាភិបាលមានភារៈទទួលខុសត្រូវលើការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន និងបង្ហាញនូវភាពត្រឹមត្រូវនៃរបាយការណ៍ហិរញ្ញវត្ថុ ដោយអនុលោមទៅតាមស្តង់ដារបាយការណ៍ហិរញ្ញវត្ថុអន្តរជាតិនៃកម្ពុជា។ ក្រុមប្រឹក្សាភិបាលក៏មានភារៈទទួលខុសត្រូវផងដែរ ចំពោះការត្រួតពិនិត្យផ្ទៃក្នុង ដូចជាការកំណត់នូវភាពចាំបាច់សម្រាប់ការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនឱ្យជៀសផុតពីការបង្ហាញខុសជាសារវន្ត ដោយសារការក្លែងបន្លំ ឬកំហុសឆ្គង។

ក្នុងការរៀបចំរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ក្រុមប្រឹក្សាភិបាលមានភារៈទទួលខុសត្រូវវាយតម្លៃលទ្ធភាពរបស់ក្រុមហ៊ុនក្នុងការបន្តនិរន្តរភាព ការបង្ហាញព័ត៌មានប្រសិនបើពាក់ព័ន្ធនូវបញ្ហាទាំងឡាយដែលទាក់ទងទៅនឹងនិរន្តរភាពអាជីវកម្ម និងប្រើប្រាស់មូលដ្ឋាននិរន្តរភាពនៃគណនេយ្យ លើកលែងតែក្រុមប្រឹក្សាភិបាលមានបំណងរំលាយក្រុមហ៊ុន ឬបញ្ឈប់ប្រតិបត្តិការ ឬគ្មានជម្រើសសមរម្យណាផ្សេងក្រៅពីធ្វើបែបនេះ។

ក្រុមប្រឹក្សាភិបាលមានភារៈកិច្ចទទួលខុសត្រូវចំពោះការត្រួតពិនិត្យដំណើរការរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន។

## ការទទួលខុសត្រូវរបស់សវនករសម្រាប់ការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុ

គោលបំណងរបស់យើងខ្ញុំ គឺផ្តល់នូវអំណះអំណាងសមហេតុផលថារបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនទាំងមូលមិនមានការបង្ហាញខុសជាសារវន្តដោយសារតែការក្លែងបន្លំ ឬកំហុសឆ្គង និងផ្តល់នូវរបាយការណ៍របស់សវនករដែលរួមបញ្ចូលមតិយោបល់នៃសវនកម្មរបស់យើងខ្ញុំ។ អំណះអំណាងសមហេតុផល គឺអំណះអំណាងមានកម្រិតខ្ពស់មួយ ប៉ុន្តែមិនមែនជាការធានាថា សវនកម្មដែលធ្វើឡើងដោយអនុលោមតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា អាចរកឃើញនូវការបង្ហាញខុសជាសារវន្តដែលបានកើតឡើងនោះទេ។ ការបង្ហាញខុសជាសារវន្តអាចកើតឡើង ដោយសារការក្លែងបន្លំ ឬកំហុសឆ្គង ឬក៏រួមបញ្ចូលគ្នា ដែលត្រូវបានរំពឹងថានឹងជះឥទ្ធិពលដល់ការសម្រេចចិត្តផ្នែកសេដ្ឋកិច្ចរបស់អ្នកប្រើប្រាស់ដោយពឹងផ្អែកលើរបាយការណ៍ហិរញ្ញវត្ថុនេះ។

ជាផ្នែកមួយនៃការធ្វើសវនកម្ម ដោយអនុលោមតាមស្តង់ដារសវនកម្មអន្តរជាតិនៃកម្ពុជា យើងខ្ញុំអនុវត្តនូវការវិនិច្ឆ័យដែលប្រកបដោយវិជ្ជាជីវៈ និងរក្សានូវមជ្ឈជាតុនិយមក្នុងកំឡុងពេលធ្វើសវនកម្ម។ យើងខ្ញុំក៏ៈ

- ធ្វើការកំណត់ និងវាយតម្លៃហានិភ័យនៃនៃការបង្ហាញខុសជាសារវន្តលើរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ដោយសារតែការក្លែងបន្លំ ឬកំហុសឆ្គង រចនា និងអនុវត្តនូវនីតិវិធីសវនកម្ម ដើម្បីឆ្លើយតបទៅនឹងហានិភ័យ
- ទាំងនោះ និងប្រមូលភស្តុតាងសវនកម្មដែលមានលក្ខណៈគ្រប់គ្រាន់ និងសមស្រប ដើម្បីជាមូលដ្ឋានសម្រាប់ធ្វើការបញ្ចេញមតិសវនកម្មរបស់យើងខ្ញុំ។ ហានិភ័យដែលមិនអាចរកឃើញនូវការបង្ហាញខុសជាសារវន្ត ដែលបណ្តាលមកពីការក្លែងបន្លំ មានលក្ខណៈខ្ពស់ជាងការបង្ហាញខុសដែលកើតឡើងពីកំហុសឆ្គង ដោយសារការក្លែងបន្លំអាចរួមបញ្ចូលទាំងការឃុបឃិតគ្នា ការក្លែងភ្លាំង ការលុបចោលដោយចេតនា បំណកស្រាយមិនពិត ឬការបំពានលើនិតិវិធីគ្រប់គ្រងផ្ទៃក្នុង។
- ទទួលបានការយល់ដឹងអំពីការគ្រប់គ្រងផ្ទៃក្នុង ដែលពាក់ព័ន្ធនឹងការធ្វើសវនកម្មក្នុងគោលបំណងរៀបចំនីតិវិធីសវនកម្មដែលសមស្របទៅតាមកាលៈទេសៈ ប៉ុន្តែមិនមែនក្នុងគោលបំណងដើម្បីបញ្ចេញមតិយោបល់លើប្រសិទ្ធភាពនៃការគ្រប់គ្រងផ្ទៃក្នុងរបស់ក្រុមហ៊ុនឡើយ។
- វាយតម្លៃលើភាពសមស្រប នៃគោលការណ៍គណនេយ្យ ដែលបានប្រើប្រាស់ និងភាពសមហេតុផលនៃការប៉ាន់ស្មានគណនេយ្យ និងការបង្ហាញព័ត៌មានពាក់ព័ន្ធដែលបានធ្វើឡើងដោយក្រុមប្រឹក្សាភិបាល។
- ធ្វើការសន្និដ្ឋានលើភាពសមស្របនៃការប្រើប្រាស់មូលដ្ឋាននិរន្តភាពរបស់ក្រុមប្រឹក្សាភិបាល និងផ្អែកលើភស្តុតាងសវនកម្មដែលទទួលបានថា តើភាពមិនច្បាស់លាស់ជាសារវន្តទាក់ទងនឹងព្រឹត្តិការណ៍ ឬលក្ខខណ្ឌដែលអាចធ្វើឱ្យមានមន្ទិលសង្ស័យជាសារវន្ត ទៅលើលទ្ធភាពរបស់ក្រុមហ៊ុនក្នុងការបន្តនិរន្តរភាពអាជីវកម្ម។ ប្រសិនបើយើងខ្ញុំសន្និដ្ឋានថា មានអត្ថិភាពនៃភាពមិនប្រាកដប្រជាជាសារវន្ត យើងខ្ញុំចាំបាច់ត្រូវបញ្ចូលនៅក្នុងរបាយការណ៍សវនកររបស់យើងខ្ញុំដើម្បីទាញចំណាប់អារម្មណ៍លើការលាតត្រដាងព័ត៌មានពាក់ព័ន្ធ នៅក្នុងរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុន ឬប្រសិនបើការបង្ហាញព័ត៌មានមានលក្ខណៈមិនគ្រប់គ្រាន់ យើងខ្ញុំចាំបាច់ត្រូវផ្តល់មតិសវនកម្មដែលមានបញ្ហា។ ការសន្និដ្ឋានរបស់យើងខ្ញុំ គឺផ្អែកលើភស្តុតាងសវនកម្មដែលប្រមូលបានត្រឹមកាលបរិច្ឆេទរបាយការណ៍សវនកររបស់យើងខ្ញុំ។ ទោះបីជាយ៉ាងណាក៏ដោយ ព្រឹត្តិការណ៍ ឬលក្ខខណ្ឌនាពេលអនាគតអាចបណ្តាលឱ្យក្រុមហ៊ុនបញ្ឈប់និរន្តរភាពនៃអាជីវកម្ម។
- វាយតម្លៃលើការបង្ហាញនៃទម្រង់ រចនាសម្ព័ន្ធ និងខ្លឹមសារនៃរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនដែលរួមបញ្ចូលទាំងការបង្ហាញព័ត៌មាន និវាយតម្លៃថាតើរបាយការណ៍ហិរញ្ញវត្ថុបានបង្ហាញពីប្រតិបត្តិការ និងព្រឹត្តិ ការណ៍នានាតាមលក្ខណៈដែលអាចសម្រេចបាននូវការបង្ហាញរបាយការណ៍ហិរញ្ញវត្ថុដ៏ត្រឹមត្រូវ។

យើងខ្ញុំបានពិភាក្សាជាមួយនឹងក្រុមប្រឹក្សាភិបាល ស្តីពីបញ្ហា វិសាលភាព និងពេលវេលាដែលបានគ្រោងទុកសម្រាប់ការធ្វើសវនកម្ម និងការរកឃើញបញ្ហាជាសារវន្តផ្សេងទៀត ដែលរួមមានចំណុចខ្វះខាតនៃការគ្រប់គ្រងផ្ទៃក្នុងដែលបានរកឃើញក្នុងអំឡុងពេលធ្វើសវនកម្ម។

យើងក៏ផ្តល់ឱ្យក្រុមប្រឹក្សាភិបាលនូវសេចក្តីថ្លែងការណ៍មួយថា យើងខ្ញុំបានអនុលោមតាមលក្ខខណ្ឌតម្រូវផ្នែកសីលធម៌ដែលពាក់ព័ន្ធទាក់ទងនឹងឯករាជ្យភាព និងដើម្បីទំនាក់ទំនងជាមួយពួកគេនូវរាល់ទំនាក់ទំនង និងបញ្ហាផ្សេងទៀតដែលអាចគិតថាត្រូវទទួលខុសត្រូវលើឯករាជ្យភាពរបស់យើង ហើយប្រសិនបើអាចអនុវត្តបានសកម្មភាពដែលបានធ្វើឡើងដើម្បីលុបបំបាត់ការគំរាមកំហែង ឬការការពារសុវត្ថិភាពត្រូវបានអនុវត្ត។

ពីបញ្ហាដែលបានទំនាក់ទំនងជាមួយក្រុមប្រឹក្សាភិបាល យើងខ្ញុំកំណត់ថាបញ្ហាទាំងនោះជាបញ្ហាដែលមានផលប៉ះពាល់ជាសារវន្តចំពោះការធ្វើសវនកម្មលើរបាយការណ៍ហិរញ្ញវត្ថុរបស់ក្រុមហ៊ុនសម្រាប់ឆ្នាំហិរញ្ញវត្ថុបច្ចុប្បន្ន និងជាបញ្ហាសវនកម្មសំខាន់។ យើងខ្ញុំពណ៌នាបញ្ហាទាំងនេះនៅក្នុងរបាយការណ៍សវនកររបស់យើងខ្ញុំ លើកលែងតែវាត្រូវបានហាមឃាត់ដោយច្បាប់ ឬបទប្បញ្ញត្តិនានា ក្នុងការលាតត្រដាងជាសាធារណៈ ឬនៅក្នុងករណីដ៏កម្របំផុត ដែលយើងខ្ញុំកំណត់ថាបញ្ហានោះមិនគួរត្រូវបានបង្ហាញ នៅក្នុងរបាយការណ៍របស់យើងខ្ញុំទេ ដោយសារការបង្ហាញពីបញ្ហានេះ នឹងបណ្តាលឱ្យមានផលវិបាកអវិជ្ជមាន ដែលត្រូវបានរំពឹងថានឹងបណ្តាលឱ្យប៉ះពាល់ដល់ផលប្រយោជន៍សាធារណៈ។

| | |
|---|---|
| **បេកឃើរ ធីលលី (ខេមបូឌា) ឯក.** | **ឧកញ៉ា** Tan Khee Meng |
| ក្រុមហ៊ុនគណនេយ្យករជំនាញ | គណនេយ្យករជំនាញ |

រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា

ថ្ងៃទី៖ 01 APR 2024